|---|---|---|---|---|---|---|---|---|---|
| ធាតុចូល | A | ទទួលបានទឹកប្រើប្រាស់គ្រប់គ្រាន់ | | | | | | មនុស្សភាគច្រើនទទួលបាននូវសេវាកម្មដែលល្មម និងចំណាយបាន ដោយរួមទាំងក្នុងពេលមានវិបត្តិ | មនុស្សតិចតួចប៉ុណ្ណោះដែលអាចទទួលបានទឹកគ្រប់គ្រាន់ជាពិសេសក្នុងពេលមានវិបត្តិ |
| | A | ទទួលបានគ្រឿងបរិក្ខាសុខាភិ បាលគ្រប់គ្រាន់ | | | | | | | |
| | A | ទទួលបានផ្ទះដែលរឹងមាំគ្រប់គ្រាន់ | | | | | | | |
| | A | ទទួលបានបណ្តាញដឹកជញ្ជូនគ្រប់គ្រាន់ | | | | | | | |
| | A | ទទួលបានថាមពលប្រើប្រាស់គ្រប់គ្រាន់ | | | | | | | |
| ផែនការ | B | តើផែនការឆ្លើយតបទៅនិងតម្រូវការហេដ្ឋារចនាសម្ព័ន្ធរបស់ឃុំដែរឬទេ? | | | | | | ផែនការថ្នាក់ឃុំនិងខេត្តដោះស្រាយនូវបញ្ហាទាំងនេះនិងវាបានឆ្លុះបញ្ជាំងពីតម្រូវសំខាន់ក្នុងឃុំ | ផែនការថ្នាក់ឃុំនិងខេត្តមិនអាចដោះស្រាយបញ្ហាទាំងនេះបានទេ |
| | C | តើការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធបញ្ចៀសនូវការកើនឡើងនូវភាពងាយរងគ្រោះដែរឬទេ(ឧទា. ពីជម្រើសនានា តើកន្លែងណាគួរកសាងផ្លូវ? | | | | | | ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធបានចាត់ទុកផលប៉ះពាល់ដែលជាប់ពាក់ព័ន្ធនិងសក្តានុពលអាកាសធាតុទៅលើមនុស្សអាចដោយសារតែការរចនារបស់ខ្លួន | ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធបានចាត់ទុកផលប៉ះពាល់ដែលជាប់ពាក់ព័ន្ធនិងសក្តានុពលអាកាសធាតុទៅលើមនុស្សអាចដោយសារតែការរចនារបស់ខ្លួននិងធ្វើអោយមានភាពងាយរងគ្រោះកាន់តែច្រើន |
| | D | តើមានធនធានគ្រប់គ្រាន់(ហរិញ្ញវត្ថុទ្រព្យសម្បត្តិនិងចំណេះដឹង) ដើម្បីអនុវត្តផែនការសកម្មភាពសំខាន់ៗដែរឬទេ? | | | | | | ពួកយើងមាននូវធនធានទាំងអស់ដែលពួកយើងត្រូវការសម្រាប់សកម្មភាពសំខាន់ៗដែលអាចអោយសម្រេចបានតម្រូវការហេដ្ឋារចនាសម្ព័ន្ធឃុំ | ពួកយើងមិនមាននូវធនធានដើម្បីគាំទ្រដល់តម្រូវការហេដ្ឋារចនាសម្ព័ន្ធឃុំទេ |
| លទ្ធផល | E | តើហេដ្ឋារចនាសម្ព័ន្ធសម្រេចបាននូវតម្រូវការរបស់ឃុំនាពេលបច្ចុប្បន្ននិងអនាគតដែរឬទេ? | | | | | | ហេដ្ឋារចនាសម្ព័ន្ធសម្រេចបាននូវកំរិតជីវភាព, សហគមន៏និងឆ្លើយតបទៅនិងតម្រូវការពេលមានវិបត្តិនាពេលបច្ចុប្បន្ននិងពេលអនាគតដែលអាចមើលឃើញទុកជាមុន | ហេដ្ឋារចនាសម្ព័ន្ធមិនអាចសម្រេចបាននូវកំរិតជីវភាព, សហគមន៏និងឆ្លើយតបទៅនិងតម្រូវការពេលមានវិបត្តិទេ |

***សហគមន៍***

| សមាសភាព | | សំនួរនៃការវាយតម្លៃ | | | | | មូលហេតុនៃការដាក់ពិន្ទុ | ពិន្ទុខ្ពស់ | ពិន្ទុទាប |
|---|---|---|---|---|---|---|---|---|---|
| ធាតុចូល | A | តើអ្នកអាចទទួលបាននូវអាហារបរិភោគគ្រប់គ្រាន់ក្នុងពេលជួបវិបត្តិដែរឬទេ? | | | | | | មនុស្សភាគច្រើនទទួលបាននូវម្ហូបអាហារគ្រប់គ្រាន់ដោយរួមទាំងពេលមានវិបត្តិ | មនុស្សតិចណាស់ដែលទទួលបានម្ហូបអាហារគ្រប់គ្រាន់ជាពិសេសនៅពេលមានវិបត្តិ |
| | B | តើក្រុមសហគមន៍ចូលរួមចំណែកក្នុងការគ្រប់គ្រងអោយមានប្រសិទ្ធិភាពចំពោះបញ្ហាជាកង្វល់និងបញ្ហាធម្មជាតិដែរឬទេ? | | | | | | ក្រុមសហគមន៍ និងបណ្ដាញដែលមាន ពួកគេជួយគាំទ្រគ្នាទៅវិញទៅមកក្នុងកំឡុងពេលនិងក្រោយពេលមានបាតុភូតធម្មជាតិ (ឧទា.រាំងស្ងួត) | ក្រុមសហគមន៍និងបណ្ដាញដែលមាន ពួកគេជួយគាំទ្រគ្នាទៅវិញទៅមកក្នុងកំឡុងពេលនិងក្រោយពេលមានបាតុភូតធម្មជាតិ(ឧទា.រាំងស្ងួត) |
| ផែនការ | C | តើសហគមន៍ទទួលបានព័ត៌មានគ្រប់គ្រាន់តាមតម្រូវការផែនការដែរឬទេ? | | | | | | ថ្នាក់ខេត្តនិងឃុំមានការយល់ដឹងល្អអំពីក្រុមផ្សេងៗនៅក្នុងឃុំនិងតម្រូវការរបស់ពួកគេ | ថ្នាក់ខេត្តនិងឃុំមានការយល់ដឹងខ្លះអំពីក្រុមផ្សេងៗនៅក្នុងឃុំប៉ុន្តែត្រូវខំប្រឹងដើម្បីកំណត់អោយបានពីតម្រូវការរបស់ពួកគេ |
| | D | តើមានធនធានដូចជា(ហរិញ្ញវត្ថុ ទ្រព្យសម្បត្តិនិងចំណេះដឹង)ក្នុងការអនុវត្តសកម្មភាពសំខាន់ៗតាមផែនការដែរឬទេ? | | | | | | ពួកយើងមាននូវធនធានទាំងអស់ដែលពួកយើងត្រូវការសម្រាប់អនុវត្តសកម្មភាពជាអាទិភាពដែលអាចកសាងសហគមន៍ជួយខ្លួនឯងបាន | ពួកយើងមិនមានធនធានដើម្បីជួយគាំទ្រសហគមន៍ដែលជួយខ្លួនឯងបានទេ |
| | E | តើសកម្មភាពរបស់រដ្ឋាភិបាលដោះស្រាយបញ្ហាជាតម្រូវការ(ឧទា.ផ្ទះ, សុខភាព, ទឹកស្អាត) របស់ជនងាយរងគ្រោះដែរឬទេ? | | | | | | ផែនការថ្នាក់ឃុំនិងខេត្តដោះស្រាយនូវបញ្ហាជាអាទិភាពទាំងនេះនិងវាបានឆ្លុះបញ្ចាំងពីតម្រូវសំខាន់ក្នុងឃុំ | ផែនការថ្នាក់ឃុំនិងខេត្តមិនអាចដោះស្រាយបញ្ហាទាំងនេះបានទេ |
| លទ្ធផល | F | តើភូមិឬឃុំអាចជួយខ្លួនឯងបានដោយរបៀបណា? | | | | | | ការកំណត់អត្តសញ្ញាណ, បណ្ដាញសង្គមនិងជំនាញដែលជួយគាំទ្រដល់សហគមន៍ដែលជាទូទៅសហគមន៍ដែលជួយខ្លួនឯងក្នុងងកំឡុងពេលមាននិងក្រោយពេលមានវិបត្តិ | សហគមន៍គឺមិនអាចជួយខ្លួនឯងបានទេ |

***បម្រែបម្រួលអាកាសធាតុនិងគ្រោះមហន្តរាយ***

| សមាសភាព | | សំនួរនៃការវង្វាយតម្លៃ | | | | | មូលហេតុនៃការដាក់ពិន្ទុ | ពិន្ទុខ្ពស់ | ពិន្ទុទាប |
|---|---|---|---|---|---|---|---|---|---|
| ធាតុចូល | A | តើប្រព័ន្ធប្រកាសព័ត៌មានទុកជាមុនដំណើរការល្អដែរឬទេ? | | | | | | មានប្រព័ន្ធប្រកាសព័ត៌មានទុកជាមុនដ៏មានប្រសិទ្ធិភាព | ប្រព័ន្ធប្រកាសព័ត៌មានទុកជាមុនមិនមានប្រសិទ្ធិភាពទេ |
| | B | តើព័ត៌មានទាន់ហេតុការណ៍ស្ដីអំពីបាតុភូតធម្មជាតិនិងភាពងាយរងគ្រោះមាននៅកំរិតថ្នាក់ឃុំដែរឬទេ? | | | | | | ព័ត៌មានទាន់ហេតុការណ៍ស្ដីអំពីបាតុភូតធម្មជាតិនិងភាពងាយរងគ្រោះគឺអាចទទួលបាននៅកំរិតថ្នាក់ឃុំ | មានព័ត៌មានទាន់ហេតុការណ៍ស្ដីអំពីបាតុភូតធម្មជាតិនិងភាពងាយរងគ្រោះតិចតួចដែលអាចទទួលបាននៅថ្នាក់ឃុំ |
| | C | តើសមាជិកសហគមន៍មានការយល់ដឹងពីព័ត៌មានដែលបានផ្ដល់ជូនដែរឬទេ? | | | | | | សហគមន៍មានការយល់ដឹងអំពីបម្រែបម្រួលអាកាសធាតុនិងជម្រើសសម្រាប់ការបន្សាំ | សហគមន៍មិនមានការយល់ដឹងទាំងការបម្រែបម្រួលអាកាសធាតុនិងជម្រើសសម្រាប់ការបន្សាំ |
| ផែនការ | D | តើឃុំមានផែនការឆ្លើយតបទៅនឹងបាតុភូតធម្មជាតិនានាដើម្បីបញ្ចៀសគ្រោះមហន្តរាយដែរឬទេ? | | | | | | ផែនការថ្នាក់ឃុំនិងខេត្តដោះស្រាយនូវបញ្ហាជាអាទិភាពទាំងនេះនិងវាបានឆ្លុះបញ្ចាំងពីតម្រូវសំខាន់ក្នុងឃុំ | ផែនការថ្នាក់ឃុំនិងខេត្តមិនអាចដោះស្រាយបញ្ហាទាំងនេះបានទេ |
| | E | តើមានធនធានដូចជា(ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិនិងចំណេះដឹង)ក្នុងការអនុវត្តសកម្មភាពសំខាន់ៗតាមផែនការដែរឬទេ | | | | | | ពួកយើងមានធនធានទាំងអស់ដែលពួកយើងត្រូវការសម្រាប់សកម្មភាពជាអាទិភាពដែលនឹងកសាងភាពធន់របស់សហគមន៍ | ពួកយើងមិនមានធនធានដើម្បីជួយគាំទ្រដល់ភាពធន់ទៅនិងអាកាសធាតុ |
| អភិបាលកិច្ច | F | តើអង្គការបានចូលរួមនៅក្នុងតួនាទីយ៉ាងសកម្មក្នុងការគ្រប់គ្រងគ្រោះមហន្តរាយនិងការបម្រែបម្រួលអាកាសធាតុដើម្បីដោះស្រាយបញ្ហាត្រួតស៊ីគ្នានេះដែរឬទេ? | | | | | | រដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាលជួបប្រជុំគ្នាយ៉ាងទៀងទាត់ហើយសកម្មភាពនោះគឺដើម្បីដាក់បញ្ចូលគ្នានិងធានាថាមានបំណ្ណញច្បាស់លាស់ចំពោះការកាត់បន្ថយគ្រោះមហន្តរាយនិងការបន្សាំនិងអាកាសធាតុ | មានតិចតួចឬគ្មាននៅការសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរនេះ |
| លទ្ធផល | G | តើសហគមន៍អាចគ្រប់គ្រងវិបត្តិនានាដែលកើតឡើងពីការបម្រែបម្រួលអាកាសធាតុបានល្អដែរឬទេ? ឧទា.ទឹកជំនន់) និងផលប៉ះពាល់ដែលមានដំណើរការយឺត (ឧទា. ការកើនឡើងកំរិតទឹកសមុទ្រ) | | | | | | សហគមន៍គឺធន់ទៅនិងផលប៉ះពាល់នៃដំណើរការនៃការផ្លាស់ប្ដូរអាកាសធាតុ(ឧទា.ការកំណត់ពេលវេលារដូវមូសុង) និងវិបត្តិធម្មជាតិ(ឧទា. ទឹកជំនន់) | សហគមន៍មិនបង្ហាញអោយឃើញពីភាពធន់អ្វីទាំងអស់ |

***អភិបាលកិច្ច***

| សមាសភាព | | សំនួរនៃការវង្វាយតម្លៃ | | | | | មូលហេតុនៃការដាក់ពិន្ទុ | ពិន្ទុខ្ពស់ | ពិន្ទុទាប |
|---|---|---|---|---|---|---|---|---|---|
| កិច្ចសហប្រតិបត្តិការ | A1 | ដោយពិនិត្យមើលឡើងវិញនៅទឹកជំនន់ឬគ្រោះរាំងស្ងួតកាលពីពេលថ្មីៗនេះធ្វើអោយយើងដឹងពីការសហការរវាងសហគមន៏និងក្រុមប្រឹក្សាឃុំ | | | | | | ការសហការរវាងក្រុមទាំងអស់គឺមានការរួមគ្នា រីកចម្រើន ធានាបានថាអ្វីគ្រប់យ៉ាងគឺរៀបចំបានល្អ | កង្វះការសហការគឺអាចកំណត់ពីសមត្ថភាពក្នុងការគ្រប់គ្រងរឿងសំខាន់នៅក្នុងឃុំ |
| | A2 | ក្រុមប្រឹក្សាឃុំនិងស្រុកនិងខេត្ត | | | | | | | |
| | A3 | ក្រុមប្រឹក្សាឃុំនិងអង្គការក្រៅរដ្ឋាភិបាល | | | | | | | |
| ការចូលរួមពាក់ព័ន្ធ | B1 | ដោយពិនិត្យមើលឡើងវិញនៅទឹកជំនន់ឬគ្រោះរាំងស្ងួតកាលពីពេលថ្មីៗនេះ តើការចូលរួមពាក់ព័ន្ធពីសំណាក់អ្នកពាក់ព័ន្ធទាំងឡាយក្នុងការងារសម្រេចចិត្តមានកម្រិតប៉ុណ្ណាដែរ? | | | | | | មាននូវសហគមន៏ដ៏ល្អដែលចូលរួមក្នុងការសម្រេចចិត្តថ្នាក់ឃុំ | មិនមានសហគមន៏ដែលចូលរួមក្នុងការសម្រេចចិត្តអ្វីនោះទេ |
| | B2 | ហើយបើសិនជាមិនមានទឹកជំនន់វិញយើងធ្វើការប្រៀបធៀបវាដោយរបៀបណា? | | | | | | | |
| ការចែករំលែកព័ត៍មាន | C1 | ដោយពិនិត្យមើលឡើងវិញនៅទឹកជំនន់ឬគ្រោះរាំងស្ងួតកាលពីពេលថ្មីៗនេះ តើកម្រិតនៃការចែកចាយព័ត៍មានរវាងសហគមន៏និងក្រុមប្រឹក្សាឃុំមានកម្រិតប៉ុណ្ណាដែរ? | | | | | | ការចែករំលែកព័ត៍មានធានាថា(ជីវភាពបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធនិងតម្រូវការសហគមន៏) ការគ្រប់គ្រងអ្វីគ្រប់យ៉ាងគឺត្រឹមត្រូវ | កង្វះការចែករំលែកព័ត៍មានគឺអាចកំណត់ពីសមត្ថភាពក្នុងការគ្រប់គ្រងរឿងសំខាន់នៅក្នុងឃុំ |
| | C2 | រវាងក្រុមប្រឹក្សាឃុំនិងស្រុក ឬថ្នាក់ខេត្តទៅនឹងអង្គការក្រៅរដ្ឋាភិបាល | | | | | | | |
| | D1 | ហើយការចែករំលែកព័ត៍មានរវាងសហគមន៏និងក្រុមប្រឹក្សាឃុំនេះមានកម្រិតប៉ុណ្ណាដែរបើប្រៀបធៀបទៅនិងពេលដែលមិនទាន់មានទឹកជំនន់? | | | | | | | |
| | D2 | រវាងក្រុមប្រឹក្សាឃុំនិងស្រុក ឬថ្នាក់ខេត្តទៅនឹងអង្គការក្រៅរដ្ឋាភិបាល | | | | | | | |

# ៣. កិច្ចពិភាក្សាអំពីគោលនយោបាយ

យើងបានដឹងពីដំបូងហើយថាការបន្សាំទៅនិងការបម្រែបម្រួលអាកាសធាតុត្រូវការការគាំទ្រដែលមានការរួបរួមគ្នា ទាំងថវិកានិងការតាមដានត្រួតពិនិត្យ។ យើងបានរៀបចំដំណើរការកិច្ចពិភាក្សាមួយដើម្បីបញ្ជាក់អោយកាន់តែច្បាស់ពីលទ្ធផលនៃការអនុវត្តនិងលទ្ធផលដែលអនុវត្តដើម្បីដោះស្រាយបញ្ហា ដោយមានការជាប់ពាក់ព័ន្ធជាមួយនិងមន្ត្រីរបស់រាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលសហគមន៍និងអ្នកវិទ្យាសាស្ត្រសំខាន់ៗជាច្រើនរូបទៀត។

## ៣.១. ផលប្រយោជន៍

កិច្ចពិភាក្សារបស់យើងមាននូវផលប្រយោជន៍ដូចខាងក្រោម(កំណត់ដោយអ្នកចូលរួម)

- *វាបង្កើននូវការយល់ដឹងអោយទូលំទូលាយ និងទំនាក់ទំនងទៅវិញទៅមកនៃធម្មជាតិចំពោះផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុនិងជាពិសេសចំពោះសង្គម* (ឧទា. គ្រោះរាំងស្ងួតនាំអោយដំណាំមិនទទួលបានផល ដំណាំមិនបានផលនាំអោយមានបំណុលជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ ហើយវានាំអោយមានចំណាកស្រុក ចំណាកស្រុកនាំអោយយុវជនមិនបានទៅសាលារៀន មិនបានទៅមើលថែដំណាំ)។

- *បង្កើននូវការយល់ដឹងអំពីបញ្ហាថ្នាក់ឃុំជាមួយថ្នាក់ខេត្ត អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយសកលវិទ្យាល័យក្នុងតំបន់...។* ពេលខ្លះលំហូរព័ត៌មានរវាងក្រុមទាំងអស់នេះគឺមិនល្អ ហើយខកខានមិនបានធ្វើការត្រួតពិនិត្យ។ ការចូលរួមរបស់សហគមន៍ក៏ជាការពង្រឹងសហគមន៍ ដើម្បីអោយចេះលើកឡើងនិងពិភាក្សានូវបញ្ហារបស់ពួកគេ។ ជាឧទាហរណ៍តម្រូវការរបស់ឃុំ-កិច្ចពិភាក្សាឃុំទៅលើការគ្រប់គ្រងប្រព័ន្ធប្រលាយស្រោចស្រព។

- *វាកំណត់អំពីឱកាសសម្រាប់ការបន្សាំដែលមាននៅក្នុងកម្មវិធីនាពេលបច្ចុប្បន្ននិងធ្វើអោយភាពដែលអាចជួយខ្លួនឯងបានល្អប្រសើរឡើង។* បើសិនជាសហគមន៏ក្លាយទៅជាមានទំលាប់ធ្វើការកត់សំគាល់ក្នុងការទទួលយកប្រភេទជាក់លាក់នៃការគាំទ្រពីភ្នាក់ងារណាមួយ (រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល....)ពួកគេប្រហែលជានិងមិនស្នើរសុំការជួយគាំទ្រពីអ្នកផ្សេងទៀតទេ ឬក៏ដឹងពីជម្រើសដែលពួកគេអាចនិងទទួលបានផលប្រយោជន៍។ ជាសំណាងល្អ ដែលថា ចំណុចទាំងនេះជាញឹកញាប់អាចជាជម្រើសសម្រាប់ការបន្សាំដែលជាការចំណាយមានប្រសិទ្ធិភាពល្អ។ ដំណើរការនេះបំបែកនូវឧបសគ្គដែលរារាំង។ ជាឧទាហរណ៍ បើសិនជាកុមារតែងតែទទួលបានស្ករគ្រាប់ ពួកគេប្រហែលជាសុំវាពីអ្នកដោយមិនដឹងថាអ្នកមានចេក សាច់មាន់ ឬក៏បាយ ឬក៏មិនដឹងថាអាហារទាំងអស់នេះជាអាហារដែលមានសារៈសំខាន់។ឧទាហរណ៍ពីសិក្ខាសាលារបស់ពួកយើង ដោយរួមបញ្ចូលទាំងការពិភាក្សាជាមួយយុវជនទៅវិញទៅមកនិង គ្រូដែលដឹកនាំការអប់រំនៅក្នុងសាលារៀននៅពេលល្ងាច សម្រាប់សិស្សដែលមិនបានទៅរៀនដោយសារតែទំនួល ខុសត្រូវស្ថានភាពជីវភាពគ្រួសារ និងមានអារម្មណ៍ថាត្រូវបានគេរើសអើងដោយសារបញ្ហានេះ។

- *វាអាចបង្កើតនូវជម្រើសសម្រាប់ការបន្សាំដែលមានការផ្លាស់ប្រែនៅពេលដែលឧបសគ្គមិនប្រែប្រួលត្រូវបានកំណត់។* នៅស្ថានភាពណាក៏ដោយ បញ្ហាខ្លះពិបាកក្នុងការដោះស្រាយ ពីព្រោះមាននូវឧបសគ្គនានាដូចជាកង្វះនូវមូលនិធិសម្រាប់ការអភិវឌ្ឍន៏ប្រព័ន្ធស្រោចស្រពឬរបាំងពាណិជ្ជកម្មជាដើម។ សិក្ខាសាលាអាចជួយក្នុងការពិភាក្សាទៅលើចំណុចនេះហើយនិងពិភាក្សាទៅលើមធ្យោបាយដើម្បីធ្វើការជុំវិញចំណុចនេះនិងដើម្បីកាត់បន្ថយផលប៉ះពាល់។ ជាឧទាហរណ៍ របាំងវពាណិជ្ជកម្មពីពាណិជ្ជករតែមួយអាចគ្រប់ដណ្តប់បាននូវព័ត៌មានទីផ្សារដែលល្អ ឬសហប្រតិបត្តិការចរចារសម្រាប់តម្លៃផលិតផលប្រសើរឡើងឬដើម្បីជៀសវៀងនូវទីផ្សារដែលមិនដំណើរការដោយធ្វើការយល់ព្រមទៅលើពេលវេលាប្រមូលផលដំណាំ។

កិច្ចពិភាក្សាគោលនយោបាយក៏មាននូវអត្ថប្រយោជន៏បន្ថែមដូចខាងក្រោមៈ

- វាផ្តល់នូវឧបករណ៍សម្រាប់ធ្វើផែនការ, កំណត់ពីបញ្ហានៃការប្រៀបធៀបពីភាពខ្លាំងនិងតម្រូវការនៅក្នុងសហគមន៍, ដែលងាយស្រួលក្នុងការចែករំលែកជាមួយអ្នកធ្វើផែនការ អង្គការក្រៅរដ្ឋាភិបាលនិងម្ចាស់ជំនួយដ៏មានសក្តានុពលផ្សេងៗទៀត
- វាក៏អាចប្រើជាឧបករណ៍សម្រាប់សកម្មភាពបន្សាំនិងធ្វើអោយលទ្ធផលល្អប្រសើរឡើង
- វាផ្តល់នូវការចំនាយនិងពេលវេលាមានប្រសិទ្ធិភាព ក្នុងការតាមដានការអភិវឌ្ឍន៏សហគមន៍នាពេលកន្លងមក។

## ៣.២. ការរៀបចំសម្រាប់កិច្ចពិភាក្សា

ទីមួយ ធ្វើការរំលឹកពីរង្វាយតម្លៃភាពធន់របស់សហគមន៍ និងរៀបចំសង្ខេបនូវពិន្ទុនិងបញ្ហាដែលស្ថិតនៅក្នុងលទ្ធផល នីមួយៗ។សេចក្តីសង្ខេបចំនួនពីរទៅបីទំព័រនៃចំណុចសំខាន់ស្ថិតនៅក្រោមចំណងជើងនីមួយៗ (ដូចជាការសង្ខេបផ្តល់ជូននៅក្នុងការ ណែនាំនេះ) គួរតែត្រូវបានរៀបចំ។ អ្នកសម្របសម្រួលអាចចាប់ផ្តើមធ្វើការកំណត់ពីជម្រើសសម្រាប់ការបន្សាំដែលមានសក្តានុពល ដោយផ្អែកទៅលើចំណេះដឹងរបស់ពួកគេចំពោះកម្មវិធីដែលមានស្រាប់ ធនធាន អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដែលកំពុងប្រតិបត្តិការ ក្នុងខេត្ត។ ទាំងអស់នេះអាចប្រើជាធាតុក្នុងការបន្ថែមកំឡុងពេលកិច្ចពិភាក្សានេះ។

ទីពីរ កំណត់និងធ្វើការអញ្ជើញអ្នកចូលរួមដែលមានសក្តានុពលដោយរួមទាំងអង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ និងសកលវិទ្យាល័យ ដែលជាអ្នកដែលអាចកំណត់ពីដំណោះស្រាយដោយផ្អែកលើកម្មវិធី  ដែលមានស្រាប់ឬដំណោះស្រាយថ្មីៗចំពោះបញ្ហាដែលបានរកឃើញ។ ហើយការចូលរួមក៏រួមបញ្ចូលផងដែរនៅក្រុមឬស្ថាប័នខាងក្រោមនេះ៖

- មន្ទីរបរិស្ថាន
- មន្ទីរផែនការ
- មន្ទីរធនធានទឹកនិងឧតុនិយម
- មន្ទីរកិច្ចការនារី
- មន្ទីរអប់រំយុវជននិងកីឡា
- មន្ទីរកសិកម្ម
- មន្ទីរអភិវឌ្ឍន៍ជនបទ
- អង្គការក្រៅរដ្ឋាភិបាល
- ម្ចាស់ជំនួយ ឧទា. រ៉ូតារី
- អ្នកវិទ្យាសាស្រ្ត/សកលវិទ្យាល័យ



*កិច្ចពិភាក្សាគោលនយោបាយឃុំល្វាក្រាំង*

## ៣.៣. របៀបវារៈនៃកិច្ចពិភាក្សានិងការសន្ទនា

***<u>ជំហានទី១</u>***

កិច្ចពិភាក្សាចំណាយពេលប្រមាណ៦ម៉ោង។វាចាប់ផ្តើមជាមួយនិងការណែនាំអំពីគោលបំណងៈ ដើម្បីធ្វើការពិនិត្យសារឡើង វិញពីការសិក្សាស្រាវជ្រាវដែលបានរកឃើញនិងនិងកំណត់ពីសកម្មភាពដែលអាចពង្រឹងដល់ការបន្សាំនិងបម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងឃុំ និងបន្ទាប់មកការណែនាំខ្លួនរបស់អ្នកចូលរួមនិងទិដ្ឋភាពទូទៅនៃសកម្មភាពដែលបានអនុវត្តកន្លងមក កិច្ចការនេះចំណាយពេលប្រមាណ៤៥នាទី។

## ជំហានទី២

ពិភាក្សាពីចំណុចសំខាន់ដែលបានរកឃើញ។ មធ្យោបាយដ៏សាមញ្ញបំផុតដើម្បីប្រើឧបករណ៍ភាពធន់របស់សហគមន៍គឺធ្វើការសង្ខេបពិន្ទុនៅក្នុងតារាង ដូចខាងក្រោមៈ

| | ជីវភាពនិងបរិស្ថាន | ហេដ្ឋារចនាសម្ព័ន្ធ | សហគមន៍ | ការគ្រប់គ្រងអាកាសធាតុនិងគ្រោះមហន្តរាយ |
|---|---|---|---|---|
| ធាតុចូលនិងព័ត៌មាន | | | | |
| វិសាលភាពនិងប្រសិទ្ធិភាពនៃផែនការ | | | | |
| មូលនិធិសម្រាប់អនុវត្តផែនការ | | | | |
| អភិបាលកិច្ចៈ | | | | |
| កិច្ចសហប្រតិបត្តិការ | | | | |
| ការចូលរួមពាក់ព័ន្ធ | | | | |
| ការចែករំលែកព័ត៌មាន | | | | |
| លទ្ធផល | | | | |

ការពន្យល់ពីតារាងជាសេចក្ដីលម្អិតៈ

- ពន្យល់ពីជួរឈរដោយពណ៌នាពីលទ្ធផលសំខាន់ៗ(ការអភិវឌ្ឍន៍ដែលមាននិរន្តភាព, ហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រដល់សហគមន៍, សហគមន៍ជួយខ្លួនឯង និងការដោះស្រាយការបម្រែបម្រួលអាកាសធាតុដ៏មានប្រសិទ្ធិភាពនិងការគ្រប់គ្រងគ្រោះមហន្តរាយ។
- ពន្យល់ពីជួរដេក – ចំណុចទាំងអស់នេះធ្វើអោយប៉ះពាល់ដល់លទ្ធភាពក្នុងការសម្រេចបាននូវលទ្ធផល –ហើយពន្យល់និងផ្ដល់នូវឧទាហរណ៍នៃសំណួរដែលបានសួរសម្រាប់ចំណុចនីមួយៗ។
- ពន្យល់ពីប្រព័ន្ធនៃការដាក់ពិន្ទុ – តើពណ៌នីមួយៗមានន័យដូចម្ដេច,ហើយចំពោះឃុំដែលបានជាប់ពាក់ព័ន្ធក្នុងការធ្វើវាយតម្លៃត្រូវធ្វើការពន្យល់ហេតុបានជាដាក់ពណ៌និង ម្ដេចមិនប្រើពណ៌ផ្សេង ជាឧទាហរណ៍ហេតុអ្វីដាក់ពិន្ទុអោយពណ៌ទឹកក្រូច ម្ដេចមិនដាក់ពណ៌លឿងឬក្រហម។
- ផ្ដល់នូវឧទាហរណ៍នៃសំណួរ, ពិន្ទុនិងមូលហេតុនៃការដាក់ពិន្ទុ
- សួរបញ្ជាក់អោយបានច្បាស់ចំពោះអ្វីដែលបានធ្វើរួចហើយ។ ត្រៀមខ្លួនដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃការប្រើប្រាស់ពិន្ទុ(នេះជាជម្រើសយ៉ាងឆាប់រហ័សនិងចំណាយមានប្រសិទ្ធិភាព, ប្រជាជនស្គាល់ពីសហគមន៍ពួកគាត់ច្បាស់ណាស់, ប្រព័ន្ធគឺគាំទ្រនិងប្រើប្រាស់ដោយអង្គការក្រៅរដ្ឋាភិបាលជាច្រើនដូចជា អាយយូស៊ីអិនIUCN សម្រាប់ធ្វើការវាយតម្លៃការគ្រប់គ្រងតំបន់អភិរក្ស, ការវាយតម្លៃធ្វើឡើងដោយប្រើនូវព័ត៌មានដែលអាចរកបានទាំងអស់និងព័ត៌មានបន្ថែមអាចប្រមូលបានប្រសិនជាត្រូវការ)។

ជំហាននេះអាចចំណាយពេលពី២០ទៅ៣០នាទី

## ជំហានទី៣

ក្រោយពីការផ្ដល់យោបល់ជាទូទៅត្រូវបានធ្វើឡើង បន្ទាប់មកចាប់ផ្ដើមដំណើរការកិច្ចពិភាក្សាពីលទ្ធផលនៃចំណុចនីមួយៗ ដោយចាប់ផ្ដើមជាមួយនិងបញ្ហាដែលសំខាន់ជាងគេ  ឧទាហរណ៍ បញ្ហាទាំងអស់នោះគឺជីវភាពនិងបរិស្ថាន អាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ។ ធ្វើការពន្យល់ជាសង្ខេបនូវសំណួរសំខាន់និងផ្ដល់នូវភាពជាក់ច្បាស់ក្នុងពេលធ្វើវាយតម្លៃ។ គន្លឹះនៃការទាំងអស់នេះអាចត្រូវបានកំណត់និងកំណត់ត្រាក្នុងកិច្ចពិភាក្សាអាចធ្វើការពិនិត្យឡើងវិញដើម្បីកំណត់ពីមូលហេតុ។ បើសិនជាមានច្រើនជាងមួយក្រុមបានបញ្ចប់ការវាយតម្លៃនេះ(ដូចជាក្នុងករណីសិក្សានៅវៀតណាម) បន្ទាប់មកទស្សនៈមួយណាផ្សេងគ្នានិងត្រូវបានពិភាក្សា។ វាជាការល្អក្នុងការដឹកនាំអ្នកតំណាងសហគមន៍ធ្វើបទបង្ហាញពីបញ្ហា ដូចនេះពួកគេអាចឆ្លើយនូវសំណួរជាបន្តបន្ទាប់។ ជំហាននេះចំណាយពេលប្រមាណពី២០ទៅ៣០នាទីសម្រាប់លទ្ធផលនីមួយៗ។

***ជំហានទី៤***

ពិភាក្សាអំពីមធ្យោបាយមានសក្តានុពលដើម្បីដោះស្រាយបញ្ហា។ សហគមន៍ប្រហែលជាត្រូវការការដឹកនាំសម្រាប់កិច្ចពិភាក្សានេះដោយប្រើប្រាស់នូវសំណួរខាងក្រោមឬសំភារៈដែលបានរៀបចំកាលពីពេលមុន។ ការពិភាក្សានេះអាចមានភាពទូលំទូលាយចំណាយពេលទី៣០ទៅ៦០នាទី។ ចំណុចពិភាក្សាដែលមានសក្តានុពលៈ

១. តើគម្រោងអ្វីរបស់ខេត្ត/អង្គការក្រៅរដ្ឋាភិបាល/សកលវិទ្យាល័យ ដែលមានជាប់ពាក់ព័ន្ធនិងការដោះស្រាយបញ្ហាដែលបានរកឃើញ/ ពិន្ទុទាប?
២. តើអ្វីដែលគួរកើតឡើងដើម្បីធ្វើអោយពិន្ទុជាក់លាក់មួយល្អប្រសើរឡើង?
៣. តើផែនការសកម្មភាពដែលមានស្រាប់វានឹងអាចធ្វើអោយពិន្ទុល្អប្រសើរឡើងទេ?បើសិនជាវាមិនអាចធ្វើអោយពិន្ទុល្អប្រសើរឡើង តើហេតុអ្វីបានជាយើងត្រូវយកសកម្មភាពទាំងនោះ?
៤. តើអ្វីដែលនាំអោយបញ្ហាអាចនិងមិនអាចផ្លាស់ប្តូរបានដោយស្រួល?
៥. តើគួរតែដោះស្រាយឧបសគ្គដែលមានការជាប់ពាក់ព័ន្ធគ្នាដោយរបៀបណា? ជាឧទាហរណ៍ ជាតុចូល(ការបែងចែកមូលនិធិ) ការធ្វើផែនការ និងនីតិវិធិអភិបាលកិច្ច។

អ្នកសម្របសម្រួលគួរតែប្រយ័ត្នចំពោះ៖

១. បញ្ជាក់ជាថ្មីថានូវគោលបំណងគឺដើម្បីធ្វើការស្វែងយល់ពីកត្តាដែលធ្វើអោយប៉ះពាល់ដល់ពិន្ទុ, កំណត់ពីកម្មវិធីដែលមានស្រាប់ឬគំនិតថ្មីៗដើម្បីដោះស្រាយបញ្ហាដែលបានបង្ហាញ, គិតអំពីជម្រើសដែលចំណាយតិច ឬជំនួយដោយធនធានមិនមែនជារូបិយវត្ថុ( ជំនាញ ចំណេះដឹង...)ដែលអាចដោះស្រាយបញ្ហា។
២. បញ្ចៀសអោយឆ្ងាយនូវការស្តីបន្ទោសទាំងថ្នាក់ខេត្ត ឬឃុំចំពោះការមិនបានធ្វើការរបស់ពួកគេ ដោយលើកឡើងថាគោលបំណងរបស់យើងគឺដើម្បីស្វែងរកដំណោះស្រាយជាគំរូនិងរបៀបដើម្បីធ្វើការរួមគ្នា
៣. ធានាថាអ្នកតំណាងនៃភាគីពាក់ព័ន្ធនិងមានការចូលរួមនិងអាចមើលឃើញពីរបៀបដែលចូលរួមគ្នាដើម្បីឈានឆ្ពោះទៅរកដំណោះស្រាយ។
៤. មើលពីគំនិតដែលជាប់ទាក់ទងគ្នានៅពេលការពិភាក្សាចាកចេញឆ្ងាយពីលទ្ធផលត្រូវទុកពេលអោយការពិភាក្សានេះបន្តពីពីរទៅបីនាទី ហើយបន្ទាប់មកអ្នកនិយាយថាអ្នកនឹងធ្វើការកត់ត្រាហើយត្រូវប្រាកដថាចំណុចនេះត្រូវបានពិភាក្សានៅពេលលទ្ធផលត្រូវបានធ្វើបទបង្ហាញ។

នៅចុងបញ្ចប់នៃកិច្ចពិភាក្សា អ្នកសម្របសម្រួលគួរតែសួរអ្នកចូលរួមនិងកត់ត្រាបញ្ជាតភ្ជាប់និងសេចក្តីថ្លែងសកម្មភាពនៃការបន្សាំដោយកត់ត្រាអ្នកដែលអាចអនុវត្តវាបាន។ ក្រដាសទំហំអេស្រ៊ី ទុកនៅលើតុសម្រាប់អោយអ្នកចូលរួមម្នាក់ៗអោយធ្វើការកត់ត្រាពីជម្រើសដែលមានសក្តានុពល ឬក៏អ្នកសម្របសម្រួលអាចសង្ខេបអ្វីដែលគាត់បានលឺនិងស្នើរសុំនូវមតិត្រលប់។
រំលឹកសារឡើងវិញនូវជំហានទី៣និង៤សម្រាប់លទ្ធផលផ្សេងទៀត



*ការផ្ទៀងផ្ទាត់រង្វាយតម្លៃភាពធន់ឃុំចំការសំរោង*

***ជំហានទី៥***

សរុបសេចក្ដីនូវរាល់ការពិភាក្សាទាំងអស់។ នេះរួមបញ្ចូលទាំង

- សង្ខេបនូវរាល់បញ្ហាសំខាន់ៗទាំងអស់, សកម្មភាពនៃការបន្សាំបានកំណត់ដើម្បីដោះស្រាយបញ្ហានិងនរណាដែលគួរជាប់ពាក់ព័ន្ធ
- ចាប់ផ្ដើមទីតាំងនៃការស្រាវជ្រាវបន្ថែមទៀតឬធ្វើការអង្កេតបើសិនជាត្រូវការ
- ផ្ដល់យោបល់ពីដំណើរការក្នុងការតាមដាន
- ស្នើរសុំនូវមតិត្រលប់ចុងក្រោយ
- ថ្លែងអំណរគុណដល់អ្នកចូលរួមនិងពន្យល់ពីជំហានបន្ទាប់ (ការផ្សព្វផ្សាយពីកំណត់ត្រា....)។

នៅប្រទេសកម្ពុជា យើងបានស្នើរអ្នកចូលរួមអោយសង្ខេប(ពេលមានកំណត់)និងចែករំលែកដោយផ្ទាល់ដូចខាងក្រោមៈ

១. ចំណុចសំខាន់ដែលពួកគាត់បានរៀន
២. សកម្មភាពមួយដែលពួកគាត់ឬស្ថាប័នរបស់ពួកគាត់អាចធ្វើដើម្បីគាំទ្រដល់ការបន្សាំ
៣. តើពួកគាត់គិតថាដំណើរការនេះនឹងមានប្រយោជន៍ចំពោះអ្នកដទៃផ្សេងទៀតដែរទេ

ការឆ្លើយតបយ៉ាងលើសលប់ពីសិក្ខាសាលាចំនួន២របស់យើង(១៦និង១៨នាក់) គឺជាសិក្ខាសាលាមួយដែលផ្ដល់ឱកាសយ៉ាងល្អដើម្បីរៀនអំពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ, ការពិភាក្សាដ៏ល្អអំពីកំរិតជីវភាព, កំណត់មធ្យោបាយដើម្បីធ្វើអោយកិច្ចសហប្រតិបត្តិការនិងការចែករំលែកព័ត៌មានល្អប្រសើរឡើង, ជួយក្នុងការកំណត់ចំណុចសក្ដានុពលសម្រាប់ការជួយខ្លួនឯងនិងអាចដំណើរការយ៉ាងងាយស្រួលដោយថ្នាក់ខេត្តដោយគ្មានការគាំទ្រពីខាងក្រៅ។

# ៤. របាយការណ៍ឃុំល្វាក្រាំង

## ៤.១. សេចក្ដីផ្ដើម

បណ្ដាញអាស៊ីប៉ាស៊ីភិចសម្រាប់ការស្រាវជ្រាវការបម្រែបម្រួលបរិស្ថានសកល (Asia Pacific Network for Global Change Research project) មានគោលបំណង *“ស្វែងយល់ពីភាពធន់របស់សហគមន៍ដែលមានលទ្ធភាពគាំទ្រទៅលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុនិងការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ”*។
ការចុះស្រាវជ្រាវក្នុងប្រទេសកម្ពុជាគឺ អនុវត្តន៏ឡើងក្រោមកិច្ចសហប្រតិបត្តិការរវាង សកលវិទ្យាល័យThe Sunshine Coast (USC) ប្រទេសអូស្រ្តាលី សកលវិទ្យាល័យបាត់ដំបង (UBB),គម្រោងជីវិតនិងធម្មជាតិរបស់អង្គការUN FAO (ក្រោមការជួយគាំទ្រពីក្រសួងបរិស្ថានកម្ពុជា)។ យើងបានធ្វើការជិតស្និតជាមួយគម្រោងជីវិតនិងធម្មជាតិរបស់អង្គការ UN FAOនៅក្នុងឃុំល្វាក្រាំង ខេត្តសៀមរាប។ សកម្មភាពដែលបានអនុវត្តន៍រួមមានៈ

- លក្ខណៈទូទៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងឃុំក្នុងការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រង់គ្រោះមហន្តរាយ
- ការវាយតម្លៃភាពងាយរងគ្រោះថ្នាក់ឃុំ
- ការវាយតម្លៃភាពធន់ថ្នាក់ឃុំ
- ការវាយតម្លៃសន្តិសុខស្បៀងនិងការចំណាកស្រុកថ្នាក់ឃុំ
- កិច្ចពិភាក្សាទៅលើការបន្សាំទៅនិងអាកាសធាតុ



*ការតំរង់ទិសឃុំល្វាក្រាំង*

## ៤.២. ការបង្ហាញពីបរិបទនិងអាទិភាពនានា

ការវិភាគទៅលើផែនការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ ( ២០១៦-២០១៨ ) បានបង្ហាញថា មានថវិការសម្រាប់គាំទ្រគួរអោយកត់សម្គាល់ក្នុងការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុ ដោយរួមមានការរៀបចំធ្វើផែនការ ការអភិវឌ្ឍន៍សមត្ថភាព ការបណ្ដុះបណ្ដាល និងកិច្ចសហប្រតិបត្តិការ។ សកម្មភាពជាច្រើនហាក់មិនទាន់មានដំណើរការនៅកម្រិតថ្នាក់ខេត្តនៅឡើយ។ នៅថ្នាក់ឃុំ ការប្រែប្រួលអាកាសធាតុមានលក្ខណៈស្មុគស្មាញនិងពាក់ព័ន្ធនឹងបញ្ហាសង្គមជាច្រើនដូចជា សន្តិសុខស្បៀង ផលប៉ះពាល់សេដ្ឋកិច្ច ដូចជាការកើនឡើងបំណុលក្រោយពេលដែលដំណាំនានារងការខូចខាត និងផលប៉ះពាល់បរិស្ថានដូចជាអសុវត្ថិភាពទឹកប្រើប្រាស់។

បញ្ហាទាំងអស់នេះតម្រូវអោយមានដំណោះស្រាយជារួមពីសំណាក់មន្ទីរអប់រំ យុវជននិងកីឡា មន្ទីរកសិកម្ម មន្ទីរធនធានទឹកនិងឧតុនិយម និងមន្ទីរបរិស្ថាន។ ដំណោះស្រាយរយៈពេលយូរសម្រាប់ជនងាយរងគ្រោះគឺគួរផ្តោតទៅលើបច្ចេកទេសកសិកម្មដែល ធន់និងអាកាសធាតុ និងការគ្រប់គ្រងទីជម្រាល និងការអភិវឌ្ឍន៏ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

កាកបាទក្រហមកម្ពុជាក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយនេះដែរដើម្បីដោះស្រាយវិបត្តិរយៈពេលខ្លីនិងជាពិសេសនៅពេលមានគ្រោះធម្មជាតិដូចជាទឹកជំនន់និងគ្រោះរាំងស្ងួត។

តារាងទី១បានបង្ហាញពីតម្រូវការជាអាទិភាពសម្រាប់ការអភិវឌ្ឍន៍ឃុំក្នុងការទទួលបាននូវធនធានជាមូលដ្ឋាន

តារាងទី១៖ ពិន្ទុនៃតម្រូវការជាអាទិភាព

| ប្រភេទ | ពិន្ទុជាអាទិភាព |
|---|---|
| ប្រព័ន្ធធារាសាស្ត្រ | ១០០ |
| ទឹក(សម្រាប់បរិភោគ) | ៤៨ |
| ជំនាញកសិកម្ម | ៣២ |
| សេវាសុខភាព | ២៤ |
| ការអប់រំ | ៦ |
| ផ្លូវ(មានគុណភាពល្អ) | 0 |

ក្រាហ្វិចខាងក្រោមបានបង្ហាញពីភាពផ្សេងគ្នាក្នុងការបែងចែកថវិការសម្រាប់គម្រោងវិនិយោគឃុំ។ ការប្រើប្រាស់ថវិការមានលក្ខណៈស្មុគ្រស្មាញហើយអាស្រ័យដោយ៖ (i) លក្ខណៈជាអាទិភាពក្នុងការរៀបចំថ្នាក់ឃុំ ស្រុក ខេត្តនិងថ្នាក់ជាតិនិងនីតិវិធីក្នុងការប្រើប្រាស់ថវិការ (ii) លទ្ធភាពថវិការសម្រាប់ប្រភេទគម្រោង (iii) ពេលវេលាសម្រាប់ប្រភេទផែនការនិងការអភិវឌ្ឍន៏។ អាទិភាពតែងតែមានការផ្លាស់ប្តូរគ្រប់ពេល។ ក្រាហ្វិចទីមួយបានបង្ហាញពីមូលហេតុដែលគ្រោះមហន្តរាយតែងតែជះឥទ្ធិពលដល់អាទិភាព និងឪកាសក្នុងការទទួលបានជម្រើសនៃការទទួលថវិការ។




**ក្រាហ្វិចទី១a៖** ដំណើររៀបចំផែនការនិងដំណាក់កាលជាក់លាក់ចាប់ពីថ្នាក់ជាតិដល់ថ្នាក់ឃុំ




**ក្រាហ្វិចទី១b៖** ជម្រើសក្នុងពេលមានវិបត្តិ (ឧទា. គ្រោះរាំងស្ងួត) មានន័យថាចំណុចអាទិភាពមិនត្រូវបានបំពេញឬអាទិភាពថ្មីៗត្រូវបានផ្លាស់ប្តូរ(ពណ៌ទឹកក្រូចបង្ហាញពីសក្តានុពលនៃការផ្លាស់ប្តូរ)

## ៤.៣. ការយល់ឃើញពីសន្តិសុខស្បៀង ការចំណាកស្រុកនិងផលប៉ះពាល់សង្គម

នៅក្នុងខែមេសាឆ្នាំ២០១៦ ក្រុមស្រាវជ្រាវបានធ្វើការជាមួយបុគ្គលិកអង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ក្នុងការវាយតម្លៃទៅលើសន្តិសុខស្បៀង ការចំណាកស្រុកនិងផលប៉ះពាល់ សង្គម។

- ៤៥%នៃគ្រួសារសរុបយ៉ាងហោចណាស់មានសមាជិកពេញវ័យម្នាក់ធ្វើការចំណាកស្រុកហើយ១៨.៣%មានសមាជិកគ្រួសារ២នាក់រឺច្រើនជាងនេះធ្វើការចំណាកស្រុក។ អ្នកចំណាកស្រុកស្ទើរតែទាំងអស់គឺជាបុរស។
- គ្រួសារនៃអ្នកមានសមាជិកធ្វើការចំណាកស្រុកចំនួនប្រហែលជា៦៩% បានឆ្លើយថាបញ្ហាអាកាសធាតុជាហេតុផលចំបងដែលធ្វើអោយពួកគេត្រូវចាកចេញ (ដោយសារតែខ្វះចំណីអាហារ ទិន្នផលមិនអំណោយផលនិងគ្រោះមហន្តរាយ ផ្សេងៗ)។
- បញ្ហាចំណាកស្រុកធ្វើអោយខ្វះខាតកម្លាំងពលកម្ម (៥០%នៃគ្រួសារ), បញ្ហាយុវជន (៥០%នៃគ្រួសារ) និងសុវត្ថិភាពស្ត្រី(៨%នៃគ្រួសារ)
- មានតែ៣១%នៃគ្រួសារប៉ុណ្ណោះត្រូវបានគេរាយការណ៍ថា មានទទួលបានចំណីអាហារបានច្រើនជាងមុនដោយសារតែការចំណាកស្រុកនិង១៦% ត្រូវបានគេដឹងថាកំពុងខ្វះខាតចំណីអាហារ។

យុទ្ធសាស្ត្ររបស់ប្រជាជនដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពស្បៀង៖

១. ខ្ចីលុយគេឬលក់ទ្រព្យសម្បត្តិ
២. រកចំណីអាហារបន្ថែមដូចជាដំឡូង
៣. ទិញចំណីអាហារបន្ថែម
៤. កាត់បន្ថយបរិមាណទទួលទានរបស់ស្ត្រីនិងកុមារ
៥. ចំណាកស្រុក
៦. ប្រមូលផលបន្ទាន់ទោះដំណាំមិនទាន់ពេលប្រមូលផលក៏ដោយ

ទិន្នន័យរបស់យើងបានបង្ហាញថាក្នុងបណ្តាអ្នកចំណាកស្រុក ពួកគេទទួលបានសុវត្ថិភាពតិចតួច ហើយក៏ពិបាកក្នុងការអនុវត្តន៏យុទ្ធសាស្ត្រទាំងបីខាងលើផងដែរ បើប្រៀបធៀបជាមួយគ្រួសារដទៃទៀត។ អ្នកចំណាកស្រុកភាគច្រើនចាកចេញពីលំនៅដ្ឋាននៅក្នុងខែតុលា ហើយមិនត្រលប់មកឃុំល្វាក្រាំងរហូតដល់ខែមិនា រឺមេសានោះទេ។ ក្រោយពីខែនោះពួកគេនឹងត្រលប់មកវិញដើម្បីអោយទាន់រដូវកាលដាំដុះនៅឆ្នាំក្រោយ។

## ៤.៤. ភាពធន់របស់សហគមន៍

យើងពិព័ណនាភាពធន់របស់សហគមន៍តាមរយៈធនធានរបស់សហគមន៍ដែលមានស្រាប់ សម្រាប់ការអភិវឌ្ឍន៍ និងតាម រយៈសមត្ថភាពក្នុងការកៀងគរដំណោះស្រាយផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ យើងបានប្រើប្រាស់ប្រភេទ ពណ៌ផ្សេងៗ ដើម្បីសម្គាល់ពីកម្រិតធនធានក្នុងការដោះ ស្រាយបញ្ហានានា (តារាងទី២៖ ពណ៌បៃតងសម្គាល់ល្អ, ពណ៌ក្រហមគឺមិនល្អ)។ ការបកស្រាយតាមរយៈពណ៌នេះអាចបង្ហាញថាតើតម្រូវការបែបណាគួរត្រូវបានបំពេញដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ចំណុចសំខាន់ៗបានពិភាក្សាដូចខាងក្រោម៖

*តារាងទី២៖ សង្ខេបពីការវាយតម្លៃភាពធន់របស់សហគមន៍*

| | ជីវភាពនិងបរិស្ថាន | ហេដ្ឋារចនាសម្ព័ន្ធ | សហគមន៍ | អាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ |
|---|---|---|---|---|
| ព័ត៍មាន | | | | |
| វិសាលភាពនិងប្រសិទ្ធិភាពផែនការ | | | | |
| ថវិការសម្រាប់ដំណើរការផែនការ | | | | |
| អភិបាលកិច្ច-កិច្ចសហប្រតិបត្តិការ | | | | |
| ការចូលរួមពាក់ព័ន្ធ | | | | |
| ការចែករំលែកព័ត៍មាន | | | | |
| លទ្ធផល | | | | |



*សិក្ខាសាលានៅឃុំល្វាក្រាំង*

**<u>ជីវភាពនិងបរិស្ថាន៖</u>** យោងតាមការពិភាក្សាអំពីជីវភាពរស់នៅរបស់ប្រជាជនទាក់ទងនឹងដំណាំដំឡូងឈើ ដែលវិនិយោគលឿននិងត្រូវការកម្លាំងពលកម្មតិច។ ជម្រើសដទៃទៀតគួរត្រូវបានពិចារណាដើម្បីកាត់បន្ថយការថយចុះព្រៃឈើនិងបំណុលពីមីក្រូហិរញ្ញវត្ថុ ដោយសារទិន្នផលដំណាំទាបនិងអតិផរណាតម្លៃកសិផលនៅទីផ្សារ។ វិធិបន្សាំមួយដែលមានប្រយោជន៍រយៈពេលវែងគឺការផ្លាស់ប្តូរបច្ចេកទេសដំណាំស្រូវអោយមាន រយៈពេលកាន់តែខ្លី ប៉ុន្តែសព្វថ្ងៃពូជស្រូវប្រភេទអាយុខ្លីនេះគឺមានការខ្វះខាតយ៉ាងខ្លាំង ហើយបច្ចេកទេសបុរាណរបស់ប្រជាជនពិបាកក្នុងការផ្លាស់ប្តូរ។

**<u>ហេដ្ឋារចនាសម្ព័ន្ធ៖</u>** មានការព្រួយបារម្ភថា អ្នកផ្តល់ជំនួយមិនបានស្តាប់ពីតម្រូវការពីប្រភេទប្រព័ន្ធធារាសាស្ត្រនិងវិធីធ្វើអោយវាប្រសើរឡើងនោះទេ។ ការទទួលបានទឹកស្អាតប្រើប្រាស់ក្នុងអំឡុងពេលគ្រោះធម្មជាតិក៏ជាបញ្ហាគួរអោយព្រួយបារម្ភផងដែរ។

**<u>ធនធានសហគមន៍៖</u>** ទទួលបានពិន្ទុសម្រាប់លទ្ធផលសម្រេចបានទាបជាងគេបំផុត ដោយសារតែមានកត្តាជះឥទ្ធិពលជាច្រើន។ កាកបាទក្រហមកម្ពុជា ជាស្ថាប័នមួយដែលធ្វើការយ៉ាងសកម្មក្នុងពេលគ្រោះមហន្តរាយហើយស្ថាប័នដទៃទៀតរួមទាំងអង្គការក្រៅរដ្ឋាភិបាល មិនមានវត្តមានក្នុងអំឡុងពេលនោះទេ។ ការគាំទ្រសម្រាប់ជនងាយរងគ្រោះគឺជាតម្រូវការដ៏ចាំបាច់ ជាពិសេសសម្រាប់គ្រួសារដែលគ្មានបុរសដោយសារពួកគេធ្វើការចំណាកស្រុក។

**<u>អាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ៖</u>** គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយដើរតួនាទីក្នុងការផ្តល់ព័ត៌មានទាន់ពេលវេលាទាក់ទងទៅនឹង ទឹកភ្លៀង ទឹកជំនន់ និងគ្រោះរាំងស្ងួត។ ទោះពួកគេទទួលបន្ទុកក្នុងការគ្រប់គ្រងគ្រោះមហន្តរាយប៉ុន្តែមិនអាចដោះស្រាយបញ្ហានានាដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនៅពេលអនាគតបាននៅឡើយ។ គណៈកម្មការទទួលបានព័ត៌មានពីការប្រែប្រួលអាកាសធាតុបានតិច។

**<u>អភិបាលកិច្ច៖</u>** ការសហប្រតិបត្តិការ ការចូលរួមពាក់ព័ន្ធ និងការចែករំលែកព័ត៌មានបានទទួលពិន្ទុចម្រុះ ដោយអាស្រ័យទៅលើសកម្មភាពរបស់អ្នកពាក់ព័ន្ធ។ អភិបាលកិច្ចដែលមានអន្តរកម្មរវាងថ្នាក់ស្រុកនិងថ្នាក់ខេត្តត្រូវបានចាត់ថាមានលក្ខណៈវិជ្ជមាន និងប្រសើរជាងទំនាក់ទំនងរវាងឃុំនិងអង្គការក្រៅរដ្ឋាភិបាល។

**<u>បញ្ហាជាអន្តរវិស័យ៖</u>** ធនធានតែងតែមានសម្រាប់សកម្មភាពផ្សេងៗ ប៉ុន្តែអ្នកវិនិយោគ(ភាគីផ្តល់ជំនួយ) តែងតែផ្តល់នូវអ្វីដែលមិនមែនជាតម្រូវការជាក់ស្តែងសម្រាប់សហគមន៍។ អាស្រ័យហេតុនេះការយល់ពីសហគមន៍នូវតម្រូវការដ៏ពិតប្រាកដ អាចជួយអោយអ្នកផ្តល់ជំនួយពង្រឹងឱកាសក្នុងការដោះស្រាយបញ្ហានានាអោយកាន់តែប្រសើរ។

## ៤.៥. ដំណើរការកិច្ចពិភាក្សាគោលនយោបាយ

កិច្ចពិភាក្សាពីគោលនយោបាយបានជាប់ពាក់ព័ន្ធជាមួយនិងស្ថាប័នដូចខាងក្រោម ហើយស្ថាប័នទាំងអស់ដែលត្រូវបានអញ្ជើញចូលរួមក៏ដោយសារតែបញ្ហាដែលបានកំណត់នៅក្នុងការវាយតម្លៃភាពធន់៖

- អ្នកតំណាងមកពីក្រសួងបរិស្ថាន
- ថ្នាក់ដឹកនាំនិងសមាជិករបស់គម្រោងជីវិតនិងធម្មជាតិរបស់អង្គការFAO
- មេឃុំ អនុឃុំ អ្នកតំណាងក្រុមប្រឹក្សានិងភូមិ
- មន្ទីរកិច្ចការនារី
- មន្ទីរធនធានទឹកនិងឧតុនិយម
- មន្ទីរបរិស្ថាន
- មន្ទីរអប់រំយុវជន និងកីឡា
- មន្ទីរកសិកម្ម

កិច្ចពិភាក្សានេះចំណាយពេលមួយថ្ងៃនិងមានកម្មវិធីដូចជា៖

១. ការណែនាំអំពីគម្រោង
២. សុន្ទរកថាស្វាគមន៍ពីអ្នកតំណាងក្រសួងបរិស្ថាន
៣. បទបង្ហាញពីលទ្ធផលសរុបនិងការងាររបស់គម្រោង
៤. បទបង្ហាញពីអង្គការFAO
៥. ការពិភាក្សាអំពីលទ្ធផលជាក់ច្បាស់ចំពោះលទ្ធផលនៃការអភិវឌ្ឍន៍នីមួយៗ(កម្រិតជីវភាពដែលមាននិរន្តរភាព និង បរិស្ថាន, ហេដ្ឋារចនាសម្ព័ន្ធសមស្រប, សហគមន៍ជួយខ្លួនឯងនិងប្រសិទ្ធិភាពនៃការគ្រប់គ្រងអាកាសធាតុ និង គ្រោះមហន្តរាយ)។
៦. ការពិភាក្សាអំពីជម្រើសសម្រាប់ការបន្សាំ និងឧបសគ្គរាំងចំពោះលទ្ធផលនៃការអភិវឌ្ឍន៍នីមួយៗ
៧. ការសង្ខេបអំពីបញ្ហាគន្លឹះនិងមធ្យោបាយដ៏មានសក្តានុពលសម្រាប់ឆ្ពោះទៅមុខនិងមេរៀនសំខាន់ៗសម្រាប់អ្នកចូលរួមធ្វើការពិភាក្សា។



*ការពិភាក្សាអាទិភាព*

## ៤.៦. ចំណុចដែលត្រូវបានពិភាក្សា

**សហគមន៍ជួយខ្លួនឯង**

ក្រុមបានធ្វើការពិភាក្សាអំពីប្រភេទបញ្ហាជាច្រើន ដោយរួមបញ្ចូលទាំងចំណុចសំខាន់ៗដូចខាងក្រោម៖

- យុវជនតែងតែជួយធ្វើការងារនៅទីវាលឬចំការ ដើម្បីធានាថាក្រុមគ្រួសាររបស់ពួកគាត់មានអាហារហូបចុកគ្រប់គ្រាន់ ចំណុចនេះមានន័យថាពួកគាត់មិនបានទៅសាលារៀនទេឬពួកគាត់ត្រូវសុំអាហារពីសាលា ឬក៏ពួកគាត់ត្រូវនាំក្រុមគ្រួសាររបស់ពួកគាត់ទៅក្នុងព្រៃដើម្បីស្វែងរកម្ហូប ដូចនេះពួកគាត់មិនអាចទៅរៀនបានទេ។ ពួកគាត់ត្រូវការនូវការបញ្ចុះបញ្ចូលដើម្បីអោយទៅសាលារៀន។ បើសិនជាកុមារត្រូវតែអវត្តមានពីសាលាដើម្បីទៅជួយគ្រួសាររបស់គាត់ គាត់នឹងប្រហែលជាមានអារម្មណ៍មិនល្អឡើយហើយនឹងមិនចង់ត្រលប់ទៅសាលារៀនវិញទេ។
- ការធ្វើអោយកំរិតជីវភាពល្អប្រសើរឡើង គឺតម្រូវអោយមាននូវការការពារឬរាំងចំពោះបញ្ហាចំណាកស្រុក។ ចំណុចនេះរួមបញ្ចូលនូវ៖ ( មានដីគ្រប់គ្រាន់, មានជំនាញផ្នែកកសិកម្ម, មានគ្រាប់ពូជដែលធន់នឹងអាកាសធាតុ, អាចទទួលបានទឹក (ត្រូវការនូវគោលនយោបាយឬគោលការណ៍សម្រាប់ចំណុចនេះ)។
- ត្រូវប្រាកដថាមិនមានយុវជនបន្ថែមទៀតទេដែលបោះបង់ចោលសាលារៀន។ មន្ទីរអប់រំយុវជននិងកីឡាត្រូវការធ្វើការជាមួយសហគមន៍ដើម្បីធ្វើអោយបច្ចេកទេសក្នុងការបង្រៀនល្អប្រសើរឡើង, ធានានូវហេដ្ឋារចនាសម្ព័ន្ធ ( ឧទា. បង្គន់និងទឹក ) និងផ្តល់នូវអាហាររូបករណ៍ចំពោះគ្រួសារក្រីក្រ។
- ភាពជោគជ័យរបស់កុមារម្នាក់ជាធម្មតាអាស្រ័យទៅលើគ្រួសារ ឪពុកម្តាយខ្លះដែលមិនបានរៀនសូត្រពួកគាត់ប្រហែលជាគិតអំពីជីវភាពរបស់គាត់មុនការអប់រំ ហើយអ្នកខ្លះផ្សេងទៀតប្រហែលជាចង់ឃើញនូវជីវិតរស់នៅផ្សេងៗគ្នាសម្រាប់កូនៗរបស់ខ្លួននិងចង់ឃើញនូវឱកាសផ្សេងៗសម្រាប់ពួកគេ។

*ជម្រើសសម្រាប់ការបន្សាំដ៏មានសក្តានុពលដែលត្រូវបានកំណត់រួមមាន៖*

| បញ្ហា | ជម្រើសសម្រាប់ការបន្សាំ | កិច្ចសហប្រតិបត្តិការដ៏មានសក្តានុពល |
|---|---|---|
| ក្មេងៗដែលឪពុកម្តាយចំណាកស្រុកដោយសារបញ្ហាអាកាសធាតុបណ្តាលអោយមានបញ្ហាអសន្តិសុខស្បៀង, មិនបានទៅសាលារៀនពីព្រោះតែកាតព្វកិច្ចចំពោះជីវភាពគ្រួសារនិងបន្ទាប់មកការរៀនសូត្រធ្លាក់ចុះនិងមានអារម្មណ៍អៀនលែងចង់ទៅសាលារៀន។ | ក្រុមស្វ័យសិក្សាឬក្លិបសិក្សា- នៅក្នុងអាគាររបស់ឃុំ, ផ្ទះរបស់មេភូមិឬនៅសាលារៀនរដ្ឋជាទីកន្លែងដែលពួកគេអាចរៀនពីយុវជនផ្សេងៗទៀត។មាននូវតម្រូវការអោយផ្តោតទៅលើថ្នាក់អក្ខរកម្ម។ ភ្លើងអគ្គិសនីសម្រាប់បំភ្លឺនិងបញ្ហាសន្តិសុខគឺជាក្តីកង្វល់ក្រោយពេលមេឃងងឹត។ ប្រហែលជាសមាជិកក្រុមប្រឹក្សាឃុំឬមេភូមិអាចជួយក្នុងការរៀបចំចំពោះចំណុចនេះ។<br>ដោយពិចារណាថាថ្នាក់រៀនបន្ថែមឬថ្នាក់សិក្សាក្រៅម៉ោងនេះគួរតែរៀនពី១ទៅ២ម៉ោងក្នុងមួយថ្ងៃ<br>បន្តយុទ្ធនាការអប់រំពីសារៈសំខាន់នៃសាលារៀនដែលមានស្រាប់។ ប្រហែលជាយើងអាចអញ្ជើញអាណាព្យាបាលអោយចូលក្នុងថ្នាក់រៀនអោយបានទៀងទាត់ | មន្ទីរអប់រំយុវជននិងកីឡា៖ កម្មវិធីក្រុមស្វ័យសិក្សាឬក្លិបសិក្សាមានហើយប៉ុន្តែនៅស្រុកវ៉ារិនមិនទាន់មាន។<br>ធ្វើការពិភាក្សាជាមួយគ្រូនិងមន្ទីរអប់រំដើម្បីពិនិត្យមើល ថាតើគួរធ្វើបែបណាទើបក្រុមស្វ័យសិក្សានេះអាចមានដំណើរការឡើងក្នុងឃុំល្វាក្រាំង។ |
| ជំនាញរបស់គ្រូបង្រៀន | កម្មវិធីឃុំដែលមានស្រាប់ | ភ្ជាប់ការទំនាក់ទំនងទៅមន្ទីរអប់រំដើម្បីធានាដល់ការបណ្តុះបណ្តាល |
| កង្វះបង្គន់និងទឹកនៅសាលារៀន | កសាងបង្គន់និងផ្តល់ទឹក | ផែនការរបស់ឃុំគួរតែឆ្លុះបញ្ចាំងពីចំណុចទាំងនេះ |

កម្មវិធីរបស់អង្គការFAOទៅលើកសិកម្មដែលធន់ឬរ៉ៃឆ្លាតនិងអាកាសធាតុនឹងដោះស្រាយនូវរាល់បញ្ហាទាំងអស់នេះ(សូមមើលប្រអប់១)។

### ប្រអប់១៖ ឧទាហរណ៍អំពីការអនុវត្តកសិកម្មដែលធន់ឬវ៉ៃឆ្លាត និងអាកាសធាតុរបស់អង្គការFAO

កសិកម្មដែលធន់ឬវ៉ៃឆ្លាតនឹងអាកាសធាតុផ្តល់នូវជម្រើសនានាសម្រាប់បរិបទទីតាំងជាក់លាក់និងគួរតែត្រូវបានបន្សាំជាមួយកសិករក្នុងតំបន់/សហគមន៍ដែលធ្វើកសិកម្ម។ ឧទាហរណ៍រួមមាន៖

- វិធីសាស្ត្រដែលផ្អែកលើប្រព័ន្ធអេកូឡូស៊ី
- កសិកម្មបែបអភិរក្ស
- សារធាតុចិញ្ចឹមដែលរួមបញ្ចូលគ្នានិងការគ្រប់គ្រងដី
- ការដាំដុះដែលប្រើចង់ឬសំណាញ់ផ្លាស់ស្ថិចគ្របពីលើ
- ដំណាំគម្រប
- បំលាស់ប្តូរនៅក្នុងប្រភេទដំណាំនិងការជ្រើសរើស
- ដំណាំចំរុះ
- ការប្រើប្រាស់ពូជដែលមានគុណភាពខ្ពស់និងសំភារៈដាំដុះរបស់ពូជប្រែប្រួល
- ការគ្រប់គ្រងសត្វល្អិត
- ការគ្រប់គ្រងស្មៅ
- ការគ្រប់គ្រងវាលស្មៅ
- ការគ្រប់គ្រងប្រព័ន្ធស្រោចស្រពនិងទឹក
- កសិកម្មសរីរាង្គ
- ការបែងចែកដី(តំបន់តាមដងទន្លេ, ដីព្រៃនៅក្នុងទិដ្ឋភាពជាដីកសិកម្ម)។

បញ្ហាដែលពិភាក្សារួមមាន៖

- ភាគច្រើនឃុំមិនដឹងទុកជាមុនពីបញ្ហាគ្រោះមហន្តរាយ ជាពិសេសព័ត៍មានអំពីខ្យល់កន្ត្រាក់បើទោះបីជាពួកគេមានមូលនិធិបំរុងទុកសម្រាប់បញ្ហានេះក៏ដោយ
- ឃុំមានការយល់ដឹងតិចតួចអំពីការប្រែប្រួលយឺតរបស់អាកាសធាតុ ដូចជាការប្រែប្រួលពេលវេលា រយៈពេល និងភាពប្រែប្រួលខ្លាំងនៃរដូវវស្សា
- មន្ទីរធនធានទឹកនិងឧតុនិយមចែករំលែកព័ត៌មានតាមរយៈប្រព័ន្ធអ៊ិនធឺណេត ឧទា. បណ្តាញសង្គមហ្វេសប៊ុក។ ទោះជាយ៉ាងណាក៏ដោយ ការទទួលបានអ៊ិនធឺណេតប្រើប្រាស់គឺនៅមានកំរិតនៅឡើយសមាប្រ់សហគមន៍
- ការតាមដានត្រួតពិនិត្យអំពីកំរិតទឹកភ្លៀងរបស់ក្រសួងធនធានទឹកនិងឧតុនិយមគឺធ្វើឡើងតាមរយៈប្រព័ន្ធផ្កាយរណបហើយវាមិនមាននូវកំរិតថ្នាក់ស្រុកឡើយឬក៏មិនត្រឹមត្រូវចំពោះកម្រិតថ្នាក់ស្រុកនេះ
- ស្បៀងអាហារសង្គ្រោះបន្ទាន់។ ស្បៀងអាហារនេះរួមមាន៖ដំឡូងមី ដំឡូង វាជាប្រភេទដំណាំមើមមួយដុះឡើងនៅក្នុងព្រៃហើយវាដុះដោយខ្លួនឯង
- ការពិភាក្សាលំអិតអំពីប្រព័ន្ធប្រលាយ។ ទ្វារទឹករវាងឃុំទាំងពីរគឺមិនដំណើរការ ហើយទ្វារទឹកដែលល្អគឺត្រូវចំណាយថវិការ($១២០០) ហើយឃុំទាំងពីរនេះមានជម្លោះនឹងគ្នាចំពោះបញ្ហានេះ។ នៅពេលដែលទឹកត្រូវបានត្រូវការនៅផ្នែកខាងលើ (ឃុំវាំរិន) ទ្វារទឹកនេះបើកហើយវាបង្ករអោយទឹកជន់លិចស្រូវនៅល្វាក្រាំងឬពួកគេមិនអាចទទួលបានទឹកនៅពេលដែលត្រូវការ។ ហើយវាក៏មានបញ្ហាចំពោះការរៀបចំប្លង់របស់ប្រលាយផងដែរ។

*ជម្រើសសម្រាប់ការបន្សាំដ៏មានសក្ដានុពលដែលត្រូវបានកំណត់រួមមាន៖*

| បញ្ហា | ជម្រើសសម្រាប់ការបន្សាំ | កិច្ចសហប្រតិបត្តិការដ៏មានសក្ដានុពល |
|---|---|---|
| ត្រូវការនូវការធ្វើអោយប្រសើរឡើងនូវទឹកសម្រាប់សាលារៀន | រៀបចំស្រះទឹកនូវសាលារៀននិងអាងស្តុបទឹក | បម្រែបម្រួលអាកាសធាតុ/អង្គការក្រៅរដ្ឋាភិបាល |
| ធ្វើអោយប្រសើរឡើងនូវការចែករំលែកព័ត៌មាន | ផ្សព្វផ្សាយអំពីការតាមដានត្រួតពិនិត្យអាកាសធាតុនៅសហគមន៍ ធ្វើអោយប្រសើរឡើងនូវការចែករំលែកព័ត៌មានរវាងមេឃុំ មេភូមិនិងសហគមន៍អំពីការព្យាករណ៍អាកាសធាតុ។ ប្រហែលជាអាចធ្វើការលៃលកថវិការរដ្ឋបាលរបស់ផែនការវិនិយោគឃុំសម្រាប់ការងារនេះ។ | មន្ទីរធនធានទឹកនិងឧតុនិយម/បម្រែបម្រួលអាកាសធាតុ |
| ការគ្រប់គ្រងប្រព័ន្ធប្រលាយស្រោចស្រព | បន្តនូវផែនការឃុំអំពីការគ្រប់គ្រងប្រលាយ និងរួមបញ្ចូលទាំងមន្ទីរធនធានទឹកនិងឧតុនិយមនៅក្នុងផែនការនេះ, ធ្វើការសម្រេចចិត្តថាតើមានទ្វារទឹកថ្មីមានប្រយោជន៍ដែរឬទេ | ស្រុក/មន្ទីរធនធានទឹកនិងឧតុនិយម/បម្រែបម្រួលអាកាសធាតុ |
| ស្បៀងអាហារសង្គ្រោះបន្ទាន់ | ត្រូវធានាថាចំណេះដឹងអំពីស្បៀងអាហារនៅពេលត្រូវការបន្ទាន់គឺត្រូវបានចែករំលែកពីមួយជំនាន់ទៅមួយជំនាន់ | មន្ទីរអប់រំយុវជននិងកីឡា/បម្រែបម្រួលអាកាសធាតុ |

**កំរិតជីវភាពនិងបរិស្ថាន**

បញ្ហាដែលបានពិភាក្សារួមមាន៖

- យោងទៅតាមការសិក្សាស្រាវជ្រាវជាមួយក្រុមគ្រួសារ គឺមិនមាននូវការទាក់ទងគ្នារវាងចំនួននៃប្រព័ន្ធស្រោចស្រព និងចំនួននៃការផលិតនូវក្នុងសហគមន៍នេះទេ។ ពេលខ្លះប្រជាជននិយាយថា ពួកគាត់អាចប្រើប្រាស់ប្រព័ន្ធស្រោចស្រពបាន បើទោះបីជាពួកគាត់អាចស្រោចស្រពបានត្រឹមតែ២០%នៃស្រូវរបស់ពួកគាត់ដែលនៅជិតប្រលាយក៏ដោយ ហើយថ្លៃនៃការចំនាយទៅលើការបូមទឹកមានតម្លៃថ្លៃ។
- កសិករខ្លះមិនឧស្សាហ៍ព្យាយាម។ ពេលខ្លះកសិករមិនទទួលបាននូវផលចំណេញផ្នែកសេដ្ឋកិច្ចពីដំណាំស្រូវ ហេតុដូចនេះហើយបានជាពួកគាត់ផ្លាស់ប្តូរទៅដាំដំឡូងមីវិញឬបោះបង់ចោលតែម្តង។ វាអាស្រ័យទៅលើតម្លៃនៃដំណាំ។ កសិករទាំងអស់នេះស្តាប់កសិករគំរូនិងធ្វើតាមនូវអ្វីដែលកសិករគំរូបានធ្វើ ដូចនេះការរៀនពីកសិករទៅកសិករគឺជារឿងមួយដ៏ល្អ ដូចដែលបានកំណត់ទិសដៅធ្វើការអប់រំដល់កសិករដែលមានការច្នៃប្រឌិតនិងបណ្តុះបណ្តាលគ្រូបង្គោលពីវិធីសាស្ត្រ។
- តម្លៃស្រូវគឺនៅទាបខ្លាំងណាស់ ពេលខ្លះប្រព័ន្ធស្រោចស្រពមិនបានផ្តល់អត្ថប្រយោជន៍ទេ។ បើទោះបីជាកសិករអាចប្រើនូវប្រព័ន្ធស្រោចស្រពបាន តែពួកគាត់ប្រហែលជាមិនប្រើវាទេ។ បើសិនជាកសិករទាំងអស់ផលិតស្រូវនៅក្នុងពេលតែមួយ តម្លៃស្រូវនិងធ្លាក់ចុះពីព្រោះតែពួកគេអាចលក់បានតែស្រូវសើម ហើយអ្នកទិញដឹងថាកសិករត្រូវការលក់វា។
- ការចំណាយនៃកម្លាំងពលកម្មតិចតួចជាមួយនិងការព្រួសគ្រាប់ពូជដោយដៃ ប៉ុន្តែការធ្វើរបៀបនេះត្រូវដកចេញបើសិនជាភ្លៀងមិនគ្រប់គ្រាន់ ហើយដីក៏នឹងក្លាយទៅជាអស់ជីវជាតិផងដែរ។
- ជំនាញដែលត្រូវការសម្រាប់ធ្វើការកែលំអរផលិតកម្មស្រូវដែលបានស្រោចស្រពគឺមានភាពខុសគ្នាទៅនិងស្រូវធម្មតា ឃុំត្រូវការរៀននូវបច្ចេកទេសទាំងអស់នេះ។ ជាឧទាហរណ៍ ស្រូវដែលនៅជិតប្រលាយងាយនឹងត្រូវបំផ្លាញដោយសារទឹកច្រើនពេកនិងត្រូវការនូវការសម្របសម្រួលចំពោះពេលវេលាដាំដុះដើម្បីបង្កើនការចំណេញផ្នែកហិរញ្ញវត្ថុ។

*ជម្រើសសម្រាប់ការបន្សាំដ៏មានសក្តានុពលដែលត្រូវបានកំណត់រួមមាន៖*

| បញ្ហា | ជម្រើសសម្រាប់ការបន្សាំ | កិច្ចសហប្រតិបត្តិការដ៏មានសក្តានុពល |
| --- | --- | --- |
| ត្រូវការរៀនពីបច្ចេកទេសកសិកម្មដែលធន់ឬរ័យឆ្លាតនឹងអាកាសធាតុ | កម្មវិធីរបស់អង្គការហ្វេរFAOដែលមានស្រាប់<br>រៀបចំទុកដាក់ឡើងវិញនៅធនាគារពូជអង្ករជាមួយនិងពូជដែលធន់និងអាកាសធាតុ<br>រៀនជំនាញថ្មីក្នុងការបង្កបង្កើនផលនិងព័ត៌មានបច្ចេកទេសទៅលើការគ្រប់គ្រងដំណាំដែលមានភាពធន់<br>ការអប់រំស្តីពីការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រខ្នាតតូច<br>ការត្រួតពិនិត្យអាកាសធាតុសហគមន៍និងការគ្រប់គ្រងស្រូវគឺត្រូវបានរួមបញ្ចូលទៅក្នុងកម្មវិធីនៅសាលា | អង្គការFAO/ មន្ទីរកសិកម្ម/<br>មន្ទីរធនធានទឹកនិងឧតុនិយម/<br>មន្ទីរអប់រំយុវជននិងកីឡា |
| ត្រូវការសម្របសម្រួលការដាំដុះនិងការប្រមូលផលដើម្បីបានចំណេញអតិបរិមានិងប្រើប្រាស់ប្រព័ន្ធស្រោចស្រពអោយមានប្រសិទ្ធិភាព | សហគមន៍កសិកម្ម[1] (AC) ៖ (១) ចែករំលែកពីរបៀបនៃការអនុវត្តល្អបំផុតក្នុងការធ្វើកសិកម្ម,<br>(២) វិនិយោគចំពោះពូជដែលធន់នឹងអាកាសធាតុ,<br>(៣) ពិភាក្សាតើនរណាគួរដាំដុះអ្វីនិងពេលណាដែលអាចទទួលបានតម្លៃថ្លៃ,<br>(៤) ចែករំលែកព័ត៌មាន(ព័ត៌មានវិទ្យា)<br>អំពីតម្លៃទីផ្សារ ដូចនេះពួកគេអាចចរចារតម្លៃជាមួយអ្នកទិញបាន។<br><br>វិនិយោគក្នុងការសំងួតស្រូវនិងការស្តុបទុក ហើយនិងធ្វើការបង្កើតនូវក្រុមសំងួតស្រូវនិងស្តុបទុកស្រូវ ដូចនេះពួកគេអាចទទួលបានតម្លៃថ្លៃ (រយៈពេលយូរ) | មន្ទីរកសិកម្ម/ មន្ទីរធនធានទឹកនិងឧតុនិយម/<br>បម្រែបម្រួលអាកាសធាតុ/<br>អង្គការក្រៅរដ្ឋាភិបាល/ អ្នកវិនិយោគឯកជន |

[1] This is the Khmer term for agricultural co-operative; co-operative is not used because of obvious historical links to Khmer Rouge regime.

# ៥. របាយការណ៍ឃុំចំការសំរោង

## ៥.១. សេចក្តីផ្តើម

បណ្តាញអាស៊ីប៉ាស៊ីភិចសម្រាប់ការស្រាវជ្រាវការបម្រែបម្រួលបរិស្ថានសកល (Asia Paciﬁc Network for Global Change Research project) មានគោលបំណង "ស្វែងយល់ពីភាពធន់របស់សហគមន៍ដែលមានលទ្ធភាពគាំទ្រទៅលើការបន្សាំ នឹងការប្រែប្រួលអាកាសធាតុនិងការរៀបចំផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ"។

ការចុះសិក្សាស្រាវជ្រាវគឺអនុវត្តន៍ឡើងក្រោមក្រោមកិច្ចសហប្រតិបត្តិការរវាង សកលវិទ្យាល័យThe Sunshine Coast (USC) ប្រទេសអូស្ត្រាលី សកលវិទ្យាល័យបាត់ដំបង (UBB) ក្រោមការជួយគាំទ្រពីក្រសួងបរិស្ថានកម្ពុជា។ សកម្មភាពដែលបានអនុវត្តន៍ក្នុងឃុំចំការសំរោងរួមមាន៖

- លក្ខណៈទូទៅរបស់ខេត្ត និងឃុំក្នុងការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ
- ការវាយតម្លៃភាពងាយរងគ្រោះក្នុងឃុំ (អ្នកចូលរួម ៣៧នាក់ក្នុងខែតុលាឆ្នាំ២០១៥ និងខែឧសភា២០១៦)
- ការចំណាកស្រុកពីក្នុងឃុំ និងការវាយតម្លៃសន្តិសុខស្បៀង (សំភាសន៍ប្រជាជនចំនួន១០០នាក់ នៅភូមិចំការសំរោង១និងក្នុងភូមិចំការសំរោង២ ក្នុងខែមេសាឆ្នាំ២០១៦
- ការវាយតម្លៃភាពធន់របស់ឃុំ (មិថុនា ឆ្នាំ២០១៦)
- កិច្ចពិភាក្សាពីគោលនយោបាយ (កញ្ញា ២០១៦)

របាយការណ៍នេះបានផ្តល់ព័ត៌មានជាមូលដ្ឋានគ្រឹះសម្រាប់សិក្ខាសាលាចុងក្រោយ នៃការរៀបចំគោលនយោបាយ។ គោលបំណងសំខាន់សម្រាប់សិក្ខាសាលានេះ គឺសម្របសម្រួលតម្រូវការជាអាទិភាពក្នុងការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុរបស់ឃុំ និងបង្ហាញអោយអ្នកពាក់ព័ន្ធដឹងថាពួកគេអាចធ្វើបានខ្លះក្នុងការឆ្លើយតបអោយកាន់តែប្រសើរក្នុងភាពធន់ទ្រាំ។



*ការតំរង់ទិសឃុំចំការសំរោង*

## ៥.២. ការបង្ហាញពីបរិបទនិងអាទិភាពនានា

ផែនការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ (២០១៦-២០១៨) បានបង្ហាញថា មានថវិកាសម្រាប់គាំទ្រគួរអោយកត់សម្គាល់ក្នុងការបន្សាំទៅនិងការប្រែប្រួលអាកាសធាតុ។ សកម្មភាពជាច្រើនហាក់មិនទាន់មានដំណើរការនៅកម្រិតថ្នាក់ខេត្តនៅឡើយ។ នៅថ្នាក់ឃុំ ការប្រែប្រួលអាកាសធាតុមានលក្ខណៈស្មុគ្រស្មាញ និងពាក់ព័ន្ធនិងបញ្ហាសង្គមជាច្រើនដូចជា សន្តិសុខស្បៀង ផលប៉ះពាល់សេដ្ឋកិច្ច ដូចជាការកើនឡើងបំណុលក្រោយពេលដែលដំណាំនានារងការខូចខាត និងផលប៉ះពាល់បរិស្ថានដូចជា អសុវត្ថិភាពទឹកប្រើប្រាស់។ បញ្ហាទាំងអស់នេះតម្រូវអោយមាន ដំណោះស្រាយជារួមពីសំណាក់មន្ទីរអប់រំយុវជននិង កីឡា មន្ទីរកសិកម្ម មន្ទីរធនធានទឹកនិងឧតុនិយម និងមន្ទីរបរិស្ថាន។កាកបាទក្រហមកម្ពុជាក៏ចូលរួមចំណែកយ៉ាងសកម្មក្នុងកិច្ចការគ្រប់គ្រងគ្រោះមហន្តរាយនេះដែរ។

មន្ទីរបរិស្ថាន (PDOE) បានថ្លែងថា ភាពរាំងស្ងួត ទឹកជំនន់ និងខ្យល់កន្ត្រាក់បានធ្វើអោយប៉ះពាល់យ៉ាងខ្លាំងដល់ដំណាំ ផ្ទះនិងទឹកសម្រាប់បរិភោគ។ ការថយចុះចំនួនដើមឈើមានន័យថា ទឹកក្រោមដីមានជំរៅជ្រៅពេកដែលធ្វើអោយប្រជាពលរដ្ឋពិបាកជីកសម្រាប់ប្រើប្រាស់។បាតុភូតធម្មជាតិបានកើតឡើងកាន់តែញឹកញាប់ពីព្រោះអត្រាទឹកភ្លៀងមិនមានភាពប្រក្រតី។ ព័ត៌មាននានាដែលទាក់ទងនិងអាកាសធាតុត្រូវបានបញ្ជូនទៅសហគមន៍តាមរយៈកាកបាទក្រហមកម្ពុជា។ បច្ចុប្បន្ននេះមន្ទីរបរិស្ថានបានយកចិត្តទុកដាក់ទៅលើតំបន់ការពារធម្មជាតិតែប៉ុណ្ណោះ ដោយសារតែកង្វះធនធានហិរញ្ញវត្ថុ និងព័ត៌មានដែលទាក់ទងនិងគម្រោងដទៃទៀត។ សព្វថ្ងៃនេះមន្ទីរធនធានទឹកនិងឧតុនិយមបានទទួលបន្ទុកក្នុងការផ្តល់ព័ត៌មានប្រកាសអាសន្នពីទឹកជំនន់។

## ៥.៣. ភាពងាយរងគ្រោះនៅក្នុងឃុំ

ពេលវេលានៃព្រឹត្តិការណ៍បានបង្ហាញនៅក្នុងក្រាហ្វិច១

*ក្រាហ្វិច១៖ ប្រតិទិនរដូវកាល*

| រដូវកាល/ព្រឹត្តិការណ៍ | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| រដូវភ្លៀង | | | | | | | √ | √ | √ | √ | | |
| រដូវក្តៅ | √ | √ | √ | √ | √ | | | | | | | √ |
| ការដាំស្រូវ | | | | | √ | √ | √ | √ | √ | | | |
| ការដាំបន្លែ | √ | √ | √ | | | | | | | | | √ |
| ពេលឈប់សម្រាក | | √ | | √ | √ | | | | √ | | √ | |
| រយៈពេលខ្វះខាតចំណីអាហារ | | | | | | √ | √ | √ | √ | √ | | |
| ជំងឺនានា | | | | | | | √ | √ | | | | |
| ទឹកជំនន់ | | | | | | | | √ | √ | √ | | |
| គ្រោះរាំងស្ងួត | | | | | | | | | | | √ | √ |
| ការដាំដំឡូងឈើ | | | | | √ | √ | | | | | | |

យោងតាមប្រវត្តិព្រឹត្តិការណ៍ឃុំចំការសំរោងបានប្រឈមនឹងគ្រោះធម្មជាតិដូចខាងក្រោម៖

- ទឹកជំនន់បានធ្វើអោយខូចខាតដំណាំផ្សេងៗ ធ្វើអោយថយចុះផលិតភាពដំណាំស្រូវ ធ្វើអោយលិចផ្លូវនិងមិនអាចប្រើប្រាស់សេវាសាធារណៈផ្សេងៗដូចជា សាលារៀន និងមណ្ឌលសុខភាព។ រយៈពេលទឹកជំនន់គឺចាប់ពី ២ដល់៤ សប្តាហ៍។ ប្រជាជនហាក់មានភាពងាយស្រួលក្នុងការដោះស្រាយបញ្ហាទឹកជំនន់ ពីព្រោះពួកគាត់បានទទួលនូវព័ត៌មានប្រកាសអាសន្នបានទាន់ពេល ពួកគាត់អាចស្តុបទឹកទុកនិងប្រើប្រាស់ទឹកសម្រាប់ស្រោចស្រពដំណាំរបស់ពួកគេ។ ការផ្តល់សេវាសុខាភិបាលក៏បានកាត់បន្ថយផលប៉ះពាល់ពីជំងឺផ្សេងៗដែលទាក់ទងនិងអនាម័យឬសត្វល្អិត។
- ខ្យល់ព្យុះដែលកើតឡើងនាពេលថ្មីៗនេះ(២០១៥) បានធ្វើអោយកើនឡើងនូវសត្វល្អិតទៅបំផ្លាញដំណាំ និងផ្ទះរបស់ប្រជាពលរដ្ឋ។ ព័ត៌មានផ្សេងៗដែលទាក់ទងនឹងខ្យល់ព្យុះគឺជាតម្រូវការចាំបាច់។ លើសពីនេះទៅទៀតការដាំដើមឈើអោយកាន់តែច្រើនអាចជួយបង្កើនទឹកក្រោមដីកាន់តែខ្លាំង។

- គ្រោះរាំងស្ងួត (២០១៥និង២០១៦) ធ្វើអោយទិន្នផលស្រូវធ្លាក់ចុះ និងធ្វើអោយមានវិបត្តិហិរញ្ញវត្ថុកើតឡើង។ គ្រោះរាំងស្ងួតនេះបណ្តាលមកពីកង្វះប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពដំណាំនិងកង្វះអាងស្តុកទឹក ប៉ុន្តែប្រជាជនមានទឹកសម្រាប់បរិភោគគ្រប់គ្រាន់។

តារាងទី២ បង្ហាញពីការកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍន៍ឃុំក្នុងក្របខ័ណ្ឌការប្រើប្រាស់ធនធានចំបងដែលមានស្រាប់។

*តារាងទី១៖ ពិន្ទុនៃតម្រូវការជាអាទិភាព*

| ប្រភេទតម្រូវការ | ពិន្ទុតម្រូវការជាអាទិភាព | ពិន្ទុការប្រើប្រាស់ជាអាទិភាព | អាទិភាពហិរញ្ញវត្ថុ | សំណើរជាអាទិភាព |
|---|---|---|---|---|
| ប្រព័ន្ធធារាសាស្ត្រ | ២ | ១ | ៣ | ៥ |
| ទឹក (សម្រាប់បរិភោគ) | ១ | ៥ | | ៤ |
| ជំនាញលើវិស័យកសិកម្ម | ២ | ១ | | ២ |
| សុខាភិបាល | ៥ | ៤ | ១ | ១ |
| ការអប់រំ | ៣ | ២ | | |
| ផ្លូវថ្នល់ (គុណភាពល្អ) | ៤ | ៣ | ២ | ៣ |

យោងតាមការពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ ហិរញ្ញប្បទានរបស់គម្រោងវិនិយោគឃុំគឺពឹងអាស្រ័យទៅលើកម្មវិធីគាំទ្ររបស់ខេត្ត។ ដោយអាស្រ័យតម្រូវការចាំបាច់ទៅលើប្រព័ន្ធធារាសាស្ត្រ និង ទឹកសម្រាប់បរិភោគពួកគាត់នឹងដោះស្រាយបញ្ហាទាំងអស់នេះ ដោយប្រើប្រាស់ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រក្រោមជំនួយរបស់រដ្ឋាភិបាលចិន។ ជំនាញលើវិស័យកសិកម្មបានចាត់ទុកជាតម្រូវការអាទិភាពសម្រាប់ប្រជាជនខ្មែរទាំងមូល ដោយសារតែវាអាចជួយបង្កើនជីវភាពរស់នៅសូម្បីតែនៅក្រៅឃុំ បើមិនដូច្នោះទេពួកគេនឹង លក់ដីបង្កបង្កើនផលរបស់ពួកគេក្នុងខណៈដែលទីក្រុងបាត់ដំបងកាន់តែលូតលាស់។ ការដាំនិងថែរក្សាដើមឈើគឺជាជម្រើសល្អមួយនៅពេលប្រព័ន្ធធារាសាស្ត្រត្រូវបានសាងសង់ ជាពិសេសនៅតាមតំបន់ដែលនៅឆ្ងាយពីទីក្រុង ពីព្រោះប្រជាជននៅទីនោះមានបទ ពិសោធន៍ក្នុងការដាំដុះរួចទៅហើយ។ យោងទៅតាមការពិភាក្សាក្រុមផងដែរ ប្រជាជនមានទឹកសម្រាប់បរិភោគស្ទើរគ្រប់ពេលវេលា។

## ៥.៤. ការយល់ឃើញពីសន្តិសុខស្បៀង ការចំណាកស្រុក និងផលប៉ះពាល់សង្គម

នៅក្នុងខែមេសា ឆ្នាំ២០១៦ ក្រុមស្រាវជ្រាវបានធ្វើការវាយតម្លៃ ទៅលើសន្តិសុខស្បៀង ការចំណាកស្រុកនិងផលប៉ះពាល់ សង្គម។

- ៤៦%នៃគ្រួសារសរុប យ៉ាងហោចណាស់មានសមាជិកពេញវ័យម្នាក់ធ្វើការចំណាកស្រុកហើយ២៤% មានសមាជិកគ្រួសារ ២នាក់ឬច្រើនជាងនេះធ្វើការចំណាកស្រុក។ អ្នកចំណាកស្រុកស្ទើរតែទាំងអស់គឺជាបុរស។
- គ្រួសារនៃអ្នកមានសមាជិកធ្វើការចំណាកស្រុកចំនួនប្រហែល ៤៧%បានឆ្លើយថាបញ្ហាអាកាសធាតុជាហេតុផលចំបងធ្វើអោយពួកគេត្រូវចាកចេញ (ដោយសារតែខ្វះចំណីអាហារ ទិន្នផលមិនអំណោយផលនិងគ្រោះមហន្តរាយផ្សេងៗ), ៥៦%ចាកឆ្ងាយពីភូមិស្រុកសម្រាប់ទៅបន្តការសិក្សានិង២០%ដោយសារមានបញ្ហាសេដ្ឋកិច្ចគ្រួសារ។
- ចំណាកស្រុកអាចធ្វើអោយជីវភាពល្អប្រសើរ ប៉ុន្តែវាបានធ្វើអោយថយចុះសុខមាលភាពយុវជន (៣១% នៃគ្រួសារដែលមានអ្នកចំណាកស្រុក) និងសុវត្ថិភាពនារី (២៧%នៃគ្រួសារដែលមានអ្នកចំណាកស្រុក) ។
- ការចំណាកស្រុកគឺកើតមានចំពោះគ្រួសារដោយមិនរើសថាតើពួកគេមានឬខ្វះចំណីអាហារនោះទេ។

## ៥.៥. ភាពធន់របស់ឃុំ

យើងពិព័ណនាភាពធន់សហគមន៍តាមរយៈធនធានរបស់សហគមន៍ដែលមានស្រាប់សម្រាប់ការអភិវឌ្ឍន៍និងតាមរយៈសមត្ថភាពក្នុងការគៀងគរដំណោះស្រាយផ្សេងៗដើម្បីឆ្លើយតបទៅនិងការប្រែប្រួលអាកាសធាតុ។ យើងបានប្រើប្រាស់ប្រភេទពណ៌ផ្សេងៗដើម្បីសម្គាល់ពីកម្រិតធនធានក្នុងការដោះស្រាយបញ្ហានានា (តារាងទី២៖ ពណ៌បៃតង សម្គាល់ល្អ, ពណ៌ក្រហមគឺមិនល្អ)។ ការបកស្រាយតាមរយៈពណ៌នេះអាចបង្ហាញថាតើតម្រូវការបែបណាគួរត្រូវបានបំពេញដើម្បីបន្សាំទៅនិងការប្រែប្រួលអាកាសធាតុ។ ចំណុចសំខាន់ៗបានពិភាក្សាដូចខាងក្រោម តាមរយៈការឆ្លើយតបលំអិត(តារាងទី៤)។

*តារាងទី២៖ សង្ខេបពីការវាយតម្លៃភាពធន់របស់សហគមន៍*

| | ជីវភាពនិងបរិស្ថាន | ហេដ្ឋារចនាសម្ព័ន្ធ | សហគមន៍ | អាកាសធាតុនិងការគ្រប់គ្រងមហន្តរាយ |
|---|---|---|---|---|
| ព័ត៌មាន | | | | |
| វិសាលភាពនិងប្រសិទ្ធភាពផែនការ | | | | |
| ថវិការសម្រាប់ដំណើរការផែនការ | | | | |
| អភិបាលកិច្ច - កិច្ចសហប្រតិបត្តិការ | | | | |
| ការចូលរួមពាក់ព័ន្ធ | | | | |
| ការចែករំលែកព័ត៌មាន | | | | |
| លទ្ធផល | | | | |

**<u>ជីវភាពនិងបរិស្ថាន៖</u>** យោងតាមការពិភាក្សាអំពីជីវភាពរស់នៅរបស់ប្រជាជន យើងសង្កេតឃើញប្រជាជនបានលក់ដីរបស់ពួកគេ ហើយបានបន្លាស់ទីទៅទីតាំងផ្សេងទៀតសម្រាប់ការងារដាំដុះរបស់ពួកគាត់។ ទោះបីជាយ៉ាងណាក៏ដោយសកម្មភាពនេះមិនមែន ជា ជម្រើសល្អសម្រាប់ប្រជាជនដែលរស់នៅឆ្ងាយទីក្រុងនោះទេ ពីព្រោះវាធ្វើអោយកាលានុវត្តភាពនៃការរស់នៅរបស់ពួកគេកាន់តែថយចុះ និងបង្កើនអោយមានគម្លាតរវាងអ្នកមាននិងអ្នកក្រកាន់តែខ្លាំង។ ចំណុចគួរពិចារណាគឺការលើកកំពស់ជីវភាពរស់នៅទៅដល់ស្ត្រីជាពិសេសគ្រួសារដែលមានជនចំណាកស្រុក។ ការពង្រឹងជំនាញកសិកម្មអោយកាន់តែប្រសើរ ជាតម្រូវដ៏ចាំបាច់ក្នុងការធានានូវកាលានុវត្តភាពជាពិសេសសម្រាប់កសិករដែលមានផ្ទៃដីកសិកម្មធំ។

**<u>ហេដ្ឋារចនាសម្ព័ន្ធ៖</u>** ការសាងសង់ផ្លូវ ប្រព័ន្ធធារាសាស្ត្រ និងការអប់រំជាតម្រូវការដែលត្រូវការការគាំទ្រជាចាំបាច់។

**<u>ធនធានសហគមន៍៖</u>** សហគមន៍ភាគច្រើនគឺពឹងផ្អែកទាំងស្រុងទៅលើអង្គការក្រៅរដ្ឋាភិបាល (NGOs) ក្នុងការដោះស្រាយបញ្ហានានាដូចជាការងារយុវជន អប់រំ បណ្ដុះបណ្ដាល និងសុវត្ថិភាពស្ត្រី។ ប៉ុន្តែការគាំទ្រប្រភេទនេះមានកម្រិតទាបក្នុងរយៈពេលថ្មីៗនេះ។ ហើយនេះជាតម្រូវការដ៏ធំបំផុតរបស់សហគមន៍។

**<u>អាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ៖</u>** ទោះបីគ្រោះរាំងស្ងួតជាបញ្ហាដ៏ធំមួយ ប៉ុន្តែបញ្ហានេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រជាជនដែលរស់នៅឆ្ងាយពីទីក្រុងខ្លាំងជាង។ ទឹកក្រោមដីមានជម្រៅជ្រៅពេក ដោយសារតែការបាត់បង់ព្រៃឈើ។

**<u>អភិបាលកិច្ច៖</u>** ការសហប្រតិបត្តិការ ការចូលរួមពាក់ព័ន្ធ និងការចែករំលែកព័ត៌មានគឺជាតម្រូវការដ៏ចាំបាច់មួយផងដែរ។ អភិបាលកិច្ចល្អគឺអាស្រ័យទៅលើសមាជិកសហគមន៍ធ្វើការរាយការណ៍ទៅប្រធានគណកម្មការអំពីបញ្ហានានា។

**<u>បញ្ហាជាអន្តរវិស័យ៖</u>** សហគមន៍ប្រឈមនឹងការបាត់បង់កម្លាំងពលកម្មជាច្រើនដោយសារតែបញ្ហាចំណាកស្រុក។ បញ្ហានេះបានរីករាលដាលកាន់តែខ្លាំងឡើង ហើយធ្វើអោយអ្នកក្រកាន់តែក្រ និងអ្នកមានកាន់តែមានតាមរយៈការជួញដូរដីធ្លីនៅខាងក្រៅឃុំ។ បញ្ហានេះធ្វើអោយមានការពិបាកក្នុងការធ្វើផែនការ ដូចជា៣០% ទៅ៥០% ប៉ុណ្ណោះអាចសម្រេចបាន។ ការរៀបចំផែនការត្រូវការផ្ដោតសំខាន់ទៅលើក្រុមប្រជាពលរដ្ឋផ្សេងៗគ្នានៅក្នុងឃុំ។ ក្នុងខណៈដែលឃុំបានកំពុងដោះស្រាយបញ្ហានានាទៅលើការប្រែប្រួលអាកាសធាតុ និងនគរូបនីយកម្ម ការបាត់បង់កម្លាំងយុវជនសម្រាប់ការផ្ដល់ការអនុវត្តន៏ដោយរួមមាន៖ (១) អភិវឌ្ឍន៏និងពង្រឹងជំនាញកសិកម្មសម្រាប់កសិករដែលបានលក់ដីទៅហើយ និងអ្នកដែលមិនទាន់លក់ (២) ដាំដើមឈើឡើងវិញដើម្បីធ្វើអោយប្រសើរឡើងនូវកម្រិតទឹកក្រោមដីនិងធ្វើអោយកើនឡើងប្រាក់ចំណូលដល់កសិករដែលមានផ្ទៃដីកសិកម្មតូច។

*តារាងទី៤៖ សំណួរនិងចម្លើយក្នុងការវាយតម្លៃភាពធន់របស់សហគមន៍*

| ***ជីវភាពរស់នៅនិងបរិស្ថាន*** | | | | |
|---|---|---|---|---|
| ធាតុចូល | A | តើសមាជិកសហគមន៍ទាំងអស់មានធនធានគ្រប់គ្រាន់/ថវិការគ្រប់គ្រាន់ក្រោយពីវិបត្តិផ្សេងៗ/បញ្ហាកង្វល់ផ្សេងៗដែរឬទេ? | | កម្រិតនៃការចំណាកស្រុកគឺខ្ពស់ (>៥០%នៃគ្រួសារសរុបមានយ៉ាងតិចសមាជិកម្នាក់រឺច្រើនបានចំណាកស្រុក) ហើយប្រជាជនកាន់តែច្រើនបានធ្វើការចំណាកស្រុកពីព្រោះពួកគេមិនមានលុយសងបំណុលនៅពេលដែលដំណាំរបស់ពួកគាត់ត្រូវខូចខាតពីគ្រោះរាំងស្ងួត។ |
| | B | តើសមាជិកសហគមន៍មានភាពងាយស្រួលក្នុងការជ្រើសរើសជីវភាពរស់នៅដែរឬទេ? | | ផ្លូវថ្នល់មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ផ្លាស់ប្តូរជីភាពរស់នៅរបស់ប្រជាជន ប៉ុន្តែការសាងសង់ គឺនៅមិនទាន់រួចរាល់នៅឡើយ។ ដីធ្លីដែលនៅជិតទីក្រុងគឺមានតម្លៃថ្លៃហើយម្ចាស់ដីអាចលក់វាហើយទៅទិញដីកសិកម្មជំនួសវិញ ក្នុងទំហំធំហើយមានទឹកស្រោចស្រពស្របគ្រប់គ្រាន់ នៅទីកន្លែងផ្សេង បើសិនបើពួកគេមានជំនាញកសិកម្ម (ដូចជានៅតំបន់វតនមណ្ឌល)។ វិស័យកសិកម្មក្នុងឃុំនេះបានជួបការលំបាកដោយសារតែខ្វះប្រព័ន្ធធារាសាស្ត្រ។ សម្រាប់ប្រជាជនដែលរស់នៅឆ្ងាយពីទីក្រុងហាក់មានជម្រើសតិចក្នុងការជួញដូរដីធ្លី ក្នុងខណៈពួកគេជួបបញ្ហាជាច្រើន ពីគ្រោះរាំងស្ងួត។ សម្រាប់ស្ត្រីដែលមានស្វាមីធ្វើការចំណាកស្រុកក៏មានជម្រើសតិចផងដែរក្នុងការចិញ្ចឹមជីវិត។ |
| ផែនការ | C | តើការរៀបចំផែនការបានឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ដែរឬទេ? | | ការរៀបចំផែនការគឺសម្រេចបាន៣០%នៃតម្រូវការជាក់ស្តែង។ ក្រុមប្រឹក្សាឃុំបានធ្វើការជាមួយ អង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហានានា ដោយសារតែក្រុមប្រឹក្សាឃុំមិនមានថវិការគ្រប់គ្រាន់។ |
| | D | តើធនធានមានគ្រប់គ្រាន់ដែរឬទេ (ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងចំណេះដឹង) ក្នុងការអនុវត្តន៏តាមផែនការសកម្មភាពសំខាន់ៗ? | | ធនធានហរិញ្ញវត្ថុគឺមិនគ្រប់គ្រាន់ទៅតាមតម្រូវការនោះទេ ដូចនេះក្រុមប្រឹក្សាឃុំត្រូវពឹងទៅលើអង្គការក្រៅរដ្ឋាភិបាលចំពោះការងារមួយចំនួនក្នុងតំបន់។ ពេលខ្លះក្រុមប្រឹក្សាធ្វើការស្នើរសុំសាងសង់ផ្លូវ ៤គ.ម ប៉ុន្តែជាក់ស្តែងទទួលបានថវិការសាងសង់ត្រឹមតែ៣០០ម៉ែត្រប៉ុណ្ណោះ។ អង្គការក្រៅរដ្ឋាភិបាលអាចជួយសម្រួលការងារទៅលើការអប់រំ, ឧទាហរណ៍ផ្តល់ជាអាហារូបករណ៍។ជាធម្មតាស្ត្រីមានជំនាញដូចជា កាត់ដេរ កែសម្ផស្សនិងធ្វើសរសៃ ប៉ុន្តែពួកគេមិនមានការងារធ្វើនៅក្នុងតំបន់នោះទេ។ |
| លទ្ធផល | E | តើអ្នកគិតថាបរិស្ថានសព្វថ្ងៃមានគុណភាពល្អដែរឬទេ? | | ចំណេះដឹងទាក់ទងនឹងអនាម័យនិងបំពុលគឺមានការកើនឡើង ប៉ុន្តែអនាម័យនិងទឹកស្អាតបរិភោគនៅតែជាកង្វល់។ |
| | F | តើអ្នកគិតថាការអភិវឌ្ឍន៏សេដ្ឋកិច្ចសព្វថ្ងៃមានកម្រិតប៉ុណ្ណាដែរ? | | ការប្រែប្រួលអាកាសធាតុនិងចំណាកស្រុកគឺជាបញ្ហាចំបងថ្មីនាពេលបច្ចុប្បន្ននេះប៉ុន្តែអ្វីៗហាក់មានភាពប្រសើរជាងមុន។ ម៉្យាងវិញទៀតគម្លាតអ្នកមាននិងអ្នកក្រកាន់តែខ្លាំង។ ដូចនេះយុវជនជំនាន់ក្រោយត្រូវការជាចាំបាច់នូវការពង្រឹងចំណេះដឹងដើម្បីទទួលបាននូវជំនាញកាន់តែប្រសើរ។ |

| ហេដ្ឋារចនាសម្ព័ន្ធ | | | | |
|---|---|---|---|---|
| ធាតុចូល | A1 | តើការទទួលបានទឹកស្អាតប្រើប្រាស់ទទួលបានគ្រប់គ្រាន់ក្នុងពេលវេលាធម្មតាដែរឬទេ? | | ទឹកសម្រាប់ស្រោចស្រពដំណាំគឺខ្វះខាត ប៉ុន្តែទឹកសម្រាប់បរិភោគមិនមែនជាបញ្ហាចោទខ្លាំងនោះទេ។ |
| | A2 | ...ក្នុងពេលវេលារាំងស្ងួត? | | ទឹកអាចនៅសល់ខ្លះហើយប្រជាជនអាចចែករំលែកគ្នា ប៉ុន្តែទោះជាយ៉ាងណាតម្រូវទឹកបន្ថែមពីទីក្រុងនៅតែត្រូវការដើម្បីបំពេញតម្រូវការ។ |
| | A3 | គ្រឿងបរិក្ខាសុខាភិបាល | | មានមណ្ឌលសុខភាពនិងឱសថខ្លះប៉ុន្តែប្រជាជនភាគច្រើនជ្រើសរើសគ្លីនិកឯងជនសម្រាប់ទទួលសេវាសុខភាព |
| | A3 | ផ្ទះដែលរឹងមាំ | | ផ្ទះរបស់ប្រជាជនគឺ ៣០%ជាថ្ម ៧០%ជាឈើចាស់ហើយមិនមានគុណភាពរឹងមាំដើម្បីទប់ខ្យល់ខ្លាំងនោះទេ |
| | A4 | បណ្តាញដឹកជញ្ជូន | | សម្រាប់ឃុំគឺមិនមានបញ្ហាចោទខ្លាំងនោះទេ |
| ផែនការ | B | តើផែនការអាចឆ្លើយតបទៅនឹងតម្រូវការហេដ្ឋារចនាសម្ព័ន្ធរបស់ឃុំដែរឬទេ? | | ផែនការចំនួន៥០%ត្រូវបានសម្រេចតាមតម្រូវការ |
| | C | តើមានធនធានដូចជា ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងចំណេះដឹងក្នុងការអនុវត្តសកម្មភាពសំខាន់ៗតាមផែនការដែរឬទេ? | | មានធនធានដូចជាផ្លូវថ្នល់ និងសេវាសុខភាពប៉ុន្តែមានអង្គការក្រៅរដ្ឋាភិបាលតិចតួចក្នុងការជួយគាំទ្រយុវជនក្នុងការអប់រំ។ មន្ត្រីថ្នាក់ខេត្តបានព្យាយាមទាក់ទងអង្គការក្រៅរដ្ឋាភិបាលទាំងឡាយដើម្បីដោះស្រាយបញ្ហាផ្សេងៗ។ |
| លទ្ធផល | D | តើហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ឬនៅសម្រាប់ឃុំនៅពេលនេះនិងពេលអនាគត? | | ហេដ្ឋារចនាសម្ព័ន្ធនៅតែជាតម្រូវការចាំបាច់ ដូចជាប្រព័ន្ធធារាសាស្ត្រនិងផ្លូវថ្នល់។ លើសពីនេះការគាំទ្រទៅលើបុរស និងស្ត្រីនៅតែជាកង្វល់។ |

| ធនធានសហគមន៍ | | | | |
|---|---|---|---|---|
| ធាតុចូល | A | តើអ្នកអាចទទួលបាននូវអាហារបរិភោគគ្រប់គ្រាន់ក្នុងពេលជួបវិបត្តិដែរឬទេ? | | កាកបាទក្រហមកម្ពុជាបានជួយស្បៀងអាហារក្នុងពេលមានគ្រោះមហន្តរាយ។ |
| | B1 B2 B3 | តើមានការជួយគាំទ្រទៅដល់ក្រុមប្រជាពលរដ្ឋនៅក្នុងសហគមន៍ទាន់ពេលវេលាដែរឬទេនៅមុនពេលទឹកជំនន់ឬគ្រោះរាំងស្ងួតកើតឡើង? | | ការទទួលបានកម្ចីមានកម្រិតទាបដោយសារអ្នកផ្តល់កម្ចីត្រូវការសេចក្តីបញ្ជាក់ពីប្រាក់ចំណូល (១៥%) និងប្រាក់សន្សំ (មានត្រឹមតែ៤០%ទោះបីជានៅក្នុងសហគមន៍មានក្រុមសន្សំក៏ដោយ) |
| | | ...ក្នុងអំឡុងពេលទឹកជំនន់និងរាំងស្ងួត | | ទទួលបានធនធានខ្លះនៅក្នុងឃុំ និងបានមកពីអ្នកចំណាកស្រុក |
| | | ...ក្រោយពេលទឹកជំនន់និងរាំងស្ងួត | | អាស្រ័យទៅលើការសន្សំ |
| | C | តើសហគមន៍ទទួលបានព័ត៌មានគ្រប់គ្រាន់តាមតម្រូវការផែនការដែរឬទេ? | | ចំណេះដឹងរបស់ប្រជាពលរដ្ឋដែលចូលរួមក្នុងក្រុមប្រឹក្សាឃុំនៅមានកម្រិតទាបនៅឡើយ ហើយពួកគេមានការងារដទៃទៀត ដែលធ្វើអោយពួកគាត់មិនអាចមកប្រជុំទៀតទាត់។ ម៉្យាងវិញទៀតប្រជាជនមិនសូវបានលើកពីបញ្ហាប្រឈមរបស់ពួកគាត់ទៅក្រុមប្រឹក្សាឃុំនោះទេ។ |

| | | | | |
|---|---|---|---|---|
| ផែនការ | D | តើមានធនធានដូចជា ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងចំណេះដឹងក្នុងការអនុវត្តន៍សកម្មភាពសំខាន់ៗ តាមផែនការដែរឬទេ? | | ធនធានគឺមានគ្រប់គ្រាន់ដែលបានមកពីគម្រោងអភិវឌ្ឍន៍ចំនួន១០ទៅ២០ ប៉ុន្តែសហគមន៍នេះអាស្រ័យទៅលើហិរញ្ញវត្ថុពីបរទេស ពីបណ្តាអ្នកមានធនធាននិងពីរដ្ឋាភិបាល។ |
| | E | តើសកម្មភាពរាជរដ្ឋាភិបាលអាចដោះស្រាយបញ្ហាតាមតម្រូវការ ដូចជាសាងសង់ផ្ទះ សេវាសុខាភិបាល និងទឹកស្អាតដល់ប្រជាជនដែលងាយរងគ្រោះដែរឬទេ? | | អង្គការក្រៅរដ្ឋាភិបាលបានផ្តល់ទីកន្លែងសុវត្ថិភាពដល់ស្ត្រី។ បញ្ហាគ្រឿងញៀនក៏ជាបញ្ហាសង្គមមួយដែរ ហើយបញ្ហានេះពិបាកដោះស្រាយណាស់បើសិនអ្នកសេពគ្រឿងញៀននោះជាសមាជិកគ្រួសាររបស់ក្រុមប្រឹក្សាឃុំ ឬ ប៉ូលីស។ បញ្ហាហិង្សាក្នុងគ្រួសារហាក់មិនមែនជាបញ្ហាកង្វល់ខ្លាំងនោះទេ ប៉ុន្តែហិង្សាហាក់កើតឡើងក្នុងចំណោមយុវជន។ មនុស្សចាស់និងស្ត្រីហាក់អាស្រ័យទៅលើអ្នកចំណាកស្រុកខ្លាំង។ ការខ្វះខាតថវិការសម្រាប់អនាម័យ គឺពឹងផ្អែកទៅលើអង្គការក្រៅរដ្ឋាភិបាលជាអ្នកជួយឧបត្ថម្ភ។ |
| លទ្ធផល | F | តើភូមិឬឃុំអាចជួយខ្លួនឯងបានដោយរបៀបណា? | | អង្គការក្រៅរដ្ឋាភិបាលក៏ខ្វះខាតថវិការក្នុងការឆ្លើយតបទៅនិងបញ្ហានានានៅក្នុងសហគមន៍ដែរ |

| ***ការគ្រប់គ្រងអាកាសធាតុនិងគ្រោះមហន្តរាយ*** | | | | |
|---|---|---|---|---|
| ធាតុចូល | A | តើប្រព័ន្ធប្រកាសព័ត៌មានទុកជាមុនដំណើរការល្អដែរឬទេ? | | ប្រព័ន្ធប្រកាសព័ត៌មាននេះទទួលបានតាមរយៈទូរស័ព្ទ ហ្វេស្សប៊ុក ទូរទស្សន៍ វិទ្យុនិងការសន្ទាផ្ទាល់ ប៉ុន្តែព័ត៌មានទាំងអស់នោះគឺមិនបានបង្ហាញព័ត៌មានលំអិតនិងជាក់ស្តែងទាំងស្រុងនោះទេ។ |
| | C | តើសមាជិកសហគមន៍អាចទទួលនិងយល់ពីបញ្ហាទាក់ទងនិងការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយដែរឬទេ? | | ពូជស្រូវដែលធន់ទៅនិងភាពរាំងស្ងួតមានតម្លៃថ្លៃ ហើយកសិករជ្រើសរើសការលក់ដីស្រែរបស់ពួកគាត់ជាវិធីងាយស្រួលជាងប្តូរទម្លាប់និងបច្ចេកទេសដាំដុះថ្មី។ បន្ទាប់មកទើបពួកគេរៀបចំផែនការជីវិតពេលក្រោយ។ |
| ផែនការ | D1 | តើឃុំមានផែនការឆ្លើយតបទៅនឹងបាតុភូតធម្មជាតិនានាដើម្បីបញ្ចៀសគ្រោះមហន្តរាយដែរឬទេ? | | ទឹកជំនន់ដែលកើតឡើងហាក់មិនមានផលប៉ះពាល់ធ្ងន់ធ្ងរនៅទីនេះនោះទេ (អាស្រ័យទៅតាមកាលប្រវត្តិបានបញ្ជាក់ថាផលប៉ះពាល់ពីទឹកជំនន់គឺនៅទាបជាងផលប៉ះពាល់ពីគ្រោះរាំងស្ងួត)។ គ្រោះរាំងស្ងួតមានផលប៉ះពាល់ធ្ងន់ធ្ងរហើយមិនអាចព្យាករណ៍បាន ឧទាហរណ៍កាលពីរដូវកាលមុនដាំដុះស្រូវមានរយៈពេលត្រឹមតែ៣ខែប៉ុណ្ណោះគឺមិនមែន៦ខែទេអាស្រ័យហេតុនេះប្រព័ន្ធធារាសាស្រ្តលើការស្រោចស្រពជាតម្រូវការដ៏ចាំបាច់សម្រាប់កសិករ |
| | D2 | ...ផែនការក្នុងការបញ្ឈប់គ្រោះមហន្តរាយនៅថ្ងៃអនាគតដែរឬទេ? | | គ្រោះរាំងស្ងួតពិបាកក្នុងការគ្រប់គ្រងណាស់ ប៉ុន្តែបើសិនជាយើងមានព្រៃឈើច្រើន វានឹងអាចទាក់ទាញទឹកភ្លៀងមកកាន់តែច្រើន។ |
| | E | តើមានធនធានដូចជា ហរិញ្ញវត្ថុ ទ្រព្យសម្បត្តិ និងចំណេះដឹងក្នុងការអនុវត្តន៍សកម្មភាពសំខាន់ៗ តាមផែនការដែរឬទេ? | | ប្រជាជននៅមិនទាន់យល់ពីផលប៉ះពាល់និងការផ្លាស់ប្តូរសម្រាប់ការងារកសិកម្មនៅឡើយទេ អាស្រ័យហេតុនេះពួកគេបានទៅធ្វើកសិកម្មនៅកន្លែងដទៃទៀត។ ធនធានក្នុងការដាំដើមឈើឡើងវិញគឺមិនមានគ្រប់គ្រាន់នោះទេ។ |

| | | | | |
|---|---|---|---|---|
| លទ្ធផល | F1 | តើសហគមន៍អាចគ្រប់គ្រងវិបត្តិនានាដែលកើតឡើងពីការប្រែប្រួលអាកាសធាតុបានល្អដែរឬទេ? (ដូចជាទឹកជំនន់) | | ការទទួលបានព័ត៌មាននិងការគាំទ្រគឺអាស្រ័យទៅលើថ្នាក់ខេត្ត។ |
| | F2 | ...គ្រប់គ្រងផលប៉ះពាល់ដែលមានល្បឿនយឺត ដូចជាគ្រោះរាំងស្ងួត? | | ប្រព័ន្ធធារាសាស្ត្រនិងការប្រើប្រាស់ទឹកគឺជាតម្រូវការដ៏ចាំបាច់។ សព្វថ្ងៃនេះប្រជាជននៅតែទន្ទឹងការសាងសង់ទំនប់និងប្រព័ន្ធធារាសាស្ត្រថ្មីៗទៀត។ |

| ***អភិបាលកិច្ច*** | | | | |
|---|---|---|---|---|
| កិច្ចសហប្រតិបត្តិការ | A1 | ដោយពិនិត្យមើលឡើងវិញនូវទឹកជំនន់ឬគ្រោះរាំងស្ងួតកាលពីពេលថ្មីៗនេះ ធ្វើអោយយើងដឹងពីការសហការរវាងសហគមន៍និងក្រុមប្រឹក្សាឃុំ | | ការឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះហាក់មានភាពលឿន, ការចូលរួមក្នុងសិក្ខាសាលា ឬប្រជុំមានភាពទៀងទាត់ដែលធ្វើអោយពួកគាត់ទទួលបានព័ត៌មានល្អ ប៉ុន្តែមានការពិភាក្សាគ្នាតិចតួចប៉ុណ្ណោះក្នុងអំឡុងពេលដែលកំពុងមានគ្រោះមហន្តរាយ |
| | A2 | ក្រុមប្រឹក្សាឃុំ ស្រុក ឬខេត្ត | | |
| | A3 | ក្រុមប្រឹក្សាឃុំនិងអង្គការក្រៅរដ្ឋាភិបាល | | |
| ការចូលរួមពាក់ព័ន្ធ | B1 | ដោយពិនិត្យមើលឡើងវិញនូវទឹកជំនន់ឬគ្រោះរាំងស្ងួតកាលពីពេលថ្មីៗនេះ តើការចូលរួមពាក់ព័ន្ធពីសំណាក់អ្នកពាក់ព័ន្ធទាំងឡាយក្នុងការងារសម្រេចចិត្តមានកម្រិតប៉ុណ្ណាដែរ? | | |
| | B2 | ហើយការចូលរួមនេះមានកម្រិតប៉ុណ្ណាដែរបើប្រៀបធៀបទៅនឹងពេលដែលមិនទាន់មានទឹកជំនន់? | | |
| ការចែករំលែកព័ត៌មាន | C1 | ដោយពិនិត្យមើលឡើងវិញនូវទឹកជំនន់ឬគ្រោះរាំងស្ងួតកាលពីពេលថ្មីៗនេះ តើកម្រិតនៃការចែកចាយព័ត៌មានរវាងសហគមន៍និងក្រុមប្រឹក្សាឃុំមានកម្រិតប៉ុណ្ណាដែរ? | | |
| | C2 | រវាងក្រុមប្រឹក្សាឃុំ និងស្រុក ឬថ្នាក់ខេត្ត ទៅនឹងអង្គការក្រៅរដ្ឋាភិបាល? | | |
| | D1 | ហើយការចែករំលែកព័ត៌មានរវាងសហគមន៍ និងក្រុមប្រឹក្សាឃុំនេះមានកម្រិតប៉ុណ្ណាដែរបើបៀបធៀបទៅនឹងពេលដែលមិនមានទឹកជំនន់? | | |
| | D2 | រវាងក្រុមប្រឹក្សាឃុំ ស្រុក ឬខេត្តទៅនឹងអង្គការក្រៅរដ្ឋាភិបាល | | |

## ៥.៦. ដំណើរការនៃកិច្ចពិភាក្សាគោលនយោបាយ

កិច្ចពិភាក្សាពីគោលនយោបាយសម្រាប់ឃុំចំការសំរោង ជាប់ពាក់ព័ន្ធជាមួយស្ថាប័នដូចខាងក្រោម ហើយស្ថាប័នទាំងអស់ដែលត្រូវបានអញ្ជើញចូលរួមក៏ដោយសារតែបញ្ហាដែលបានកំណត់នៅក្នុងការវាយតម្លៃភាពធន់៖

- សកលវិទ្យាល័យបាត់ដំបង, មហាវិទ្យាល័យសង្គមសាស្ត្រនិងអភិវឌ្ឍន៍សហគមន៍
- សកលវិទ្យាល័យបាត់ដំបង, មហាវិទ្យាល័យកសិកម្ម
- អង្គការផ្ទះទឹកដូង, អង្គការក្នុងតំបន់ដែលមានសកម្មភាពក្នុងសហគមន៍(PTD)
- ក្រុមរ៉ូតារីក្លិបមកពីប្រទេសអូស្ត្រាលី
- មន្ទីរកសិកម្ម(PDA)
- មេឃុំ
- តំណាងក្រុមប្រឹក្សាឃុំ (២)
- មេភូមិចំការសំរោង១និង២
- មន្ទីរកិច្ចការនារី (PDWA)
- មន្ទីរធនធានទឹកនិងឧតុនិយម (PDWR)
- មន្ទីរបរិស្ថាន (PDOE)
- មន្ទីរអប់រំ (PDE)

កិច្ចពិភាក្សានេះចំណាយពេលមួយថ្ងៃនិងមានកម្មវិធីដូចជា៖

១. ការណែនាំអំពីគម្រោង
២. ការពិភាក្សាអំពីបម្រែបម្រួលអាកាសធាតុនៅកម្ពុជា
៣. បទបង្ហាញពីលទ្ធផលសរុបនិងការងាររបស់គម្រោង
៤. ការពិភាក្សាអំពីលទ្ធផលជាក់ច្បាស់ចំពោះលទ្ធផលនៃការអភិវឌ្ឍន៍នីមួយៗ ( កម្រិតជីវភាពដែលមាននិរន្តរភាព និងបរិស្ថាន, ហេដ្ឋារចនាសម្ព័ន្ធសមស្រប, សហគមន៍ជួយខ្លួនឯងនិងប្រសិទ្ធិភាពនៃការគ្រប់គ្រងអាកសធាតុនិងគ្រោះមហន្តរាយ)។
៥. ការចូលរួមចែករំលែករបស់អង្គការផ្ទះទឹកដូងស្ដីពីបញ្ហារបស់សហគមន៍និងគម្រោងនៅក្នុងឃុំ
៦. ការពិភាក្សាអំពីជម្រើសសម្រាប់ការបន្សាំ និងឧបសគ្គរាំង ចំពោះលទ្ធផលនៃការអភិវឌ្ឍន៍នីមួយៗ
៧. ការសង្ខេបអំពីបញ្ហាគន្លឹះនិងមធ្យោបាយដ៏មានសក្ដានុពលសម្រាប់ឆ្ពោះទៅមុខ និងមេរៀនសំខាន់ៗសម្រាប់អ្នកចូលរួមធ្វើការពិភាក្សា។

យើងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីពិភាក្សាគ្នាអំពីហេដ្ឋារចនាសម្ព័ន្ធ ហើយគិតថាវាមានលទ្ធភាពតិចតួចណាស ដែលអាចធ្វើបានអំពីប្រព័ន្ធស្រោចស្រពក្នុងរយៈពេលខ្លី បើសិនជាអ្នកអភិវឌ្ឍន៍ចិនមិនទាន់សាងសង់ប្រលាយមេរួច។ បញ្ហាដែលទាក់ទងទៅនឹងអភិបាលកិច្ចត្រូវបានដាក់បញ្ចូលតាមរយៈកិច្ចពិភាក្សាចំពោះអ្នកដែលអាចធ្វើការដោះស្រាយបញ្ហាទាំងនេះបាននិងកាចំណាយប្រកបដោយប្រសិទ្ធិភាព។

## ៥.៧. ចំណុចដែលត្រូវបានពិភាក្សា

### ពិន្ទុលទ្ធផលសរុប

ការវាយតម្លៃភាពធន់របស់សហគមន៍ចំការសំរោងជារួមបង្ហាញថាមាននូវការព្រួយបារម្ភចំពោះលទ្ធផលនៃការអភិវឌ្ឍន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ ហើយវាមិនទាន់ធ្វើអន្តរកម្មចំពោះផលប៉ះពាល់ទៅលើលទ្ធផលផ្សេងៗទៀតទេ - នេះជាអ្វីមួយដែលអ្នកចូលរួមទទួលស្គាល់ក្នុងពេលសិក្ខាសាលា។

### សហគមន៍ជួយខ្លួនឯង

អង្គការផ្ទះទឹកដូងបច្ចុប្បន្ននេះស្ថិតនៅក្នុងអតីតសាលាភាសាបារាំងនៅក្នុងឃុំ។ អង្គការនេះផ្ដល់នូវលក្ខណៈទូទៅពីសកម្មភាពរបស់ខ្លួននៅក្នុងឃុំនិងពីបញ្ហាដែលពួកគេប្រឈម។

- ការផ្លាស់ប្ដូរពីអង្គការដែលផ្ដោតទៅលើជនដែលគ្មានផ្ទះសំបែងនិងជនដែលត្រូវបានរំលោភបំពាន ( ការអភិវឌ្ឍន៍ជំនាញនិងសុវត្ថិភាព) ទៅជាអង្គការដែលផ្ដល់ការអប់រំក្រៅប្រព័ន្ធ( កុំព្យូទ័រ, ភាសាអង់គ្លេសនិងកម្មវិធីអាហាររូបត្ថម្ភកុមារ) និងអនាគតផ្ដោតទៅលើសហគ្រាសខ្នាតតូចនិងអាហារូបត្ថម្ភនៅក្នុងសាលារៀននិងសហគមន៏។
- ការអប់រំនិងអាហាររូបត្ថម្ភមាននូវចំនួនកំណត់ចំពោះកុមារដែលឪពុកម្ដាយចំណាកស្រុកហើយតាយាយរបស់ពួកគេត្រូវការអោយគេជួយការងារនៅផ្ទះ( និងនៅក្នុងទីវាល) កំឡុងពេលថ្ងៃ។
- ការស្រាវជ្រាវពីគម្រោងសួនច្បារសហគមន៏សម្រាប់ពេលអនាគតទាក់ទងនិងផលិតផលតែផ្សំពីរុក្ខជាតិ ដោយប្រើប្រាស់ផ្ទៃដីសាលារៀន( បញ្ហានេះត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចពិភាក្សាពីកំរិតជីវភាព)។
- ម្ចាស់ជំនួយធំៗបានចាកចេញពីសហគមន៏ហើយវត្តមានម្ចាស់ជំនួយតូចៗនៅតែមានប៉ុន្តែពួកគេមិនអាចដោះស្រាយបញ្ហាដែលជាតម្រូវការរបស់សហគមន៏ទាំងអស់បាននោះទេ។ក្រុមបានធ្វើការពិភាក្សាអំពីសក្ដានុពលនៃគម្រោងដាំតែធម្មជាតិនៅអង្គការផ្ទះទឹកដូងនិងប្រហែលជាអាចនៅកសិដ្ឋានរបស់សកលវិទ្យាល័យបាត់ដំបងនិងជាមួយគម្រោងនិស្សិតសកលវិទ្យាល័យបាត់ដំបង ឆ្លងតាមបទពិសោធន៏របស់អ្នកចូលរួមគេធ្លាប់បានឃើញអំពីការលក់តែធម្មជាតិទៅដល់អ្នកទេសចរណ៍នៅក្នុងវត្តអារាមនៅប្រទេសថៃហើយវាក៏ជាតម្រូវការសម្រាប់ការផលិតជីកំប៉ុសសម្រាប់សហគមន៏និងសួនដំណាំនៅផ្ទះ។ អ្នកចូលរួមក៏បានពិភាក្សាផងដែរពីតម្រូវការសម្រាប់កំរិតជីវភាពសមរម្យសម្រាប់រយៈពេលយូរដើម្បីបញ្ឈប់វដ្ដនៃការលក់ដី-ក្លាយទៅជាជនគ្មានផ្ទះសំបែង-ចាប់យកដីនៅកន្លែងថ្មីដោយខុសច្បាប់-លក់ដី និងក្លាយទៅជាជនគ្មានផ្ទះសំបែងសារជាថ្មី។ ចុងក្រោយ អ្នកចូលរួមបានពិភាក្សាអំពីកន្លែងចាក់សំរាមដែលនៅជិតផ្លូវទឹកដែលវាបង្កនៅបញ្ហាសុខភាព ហើយចំពោះការចំណាយក្នុងការតបណ្ដាញទឹកស្អាតរបស់រដ្ឋគឺចំណាយ ($២៣០ក្នុងមួយគ្រួសារឬ$១០០សម្រាប់អ្នកដែលមានប័ណ្ណក្រីក្រ)។ មន្ទីរអប់រំបានលើកឡើងពីតម្រូវការនូវសកម្មភាពនានាដើម្បីអោយត្រូវទៅនិងបរិបទរបស់សហគមន៏ ឧទាហរណ៏មានថ្នាក់រៀនសម្រាប់កុមារពេលនៅពេលដែលពួកគេទំនេរពីការជួយការងារផ្ទះហើយនិងការបង្រៀនក្រុមគ្រួសារនៅក្នុងសហគមន៏អោយចេះដាំដុះបន្លែនៅផ្ទះជាជាងបញ្ជូនកូនៗអោយទៅសាលារៀនឬមណ្ឌលកុមារកំព្រាដើម្បីទទួលបានអាហារ។

ជម្រើសសម្រាប់ការបន្សាំដ៏មានសក្ដានុពលដែលត្រូវបានកំណត់រួមមាន៖

| បញ្ហា | ជម្រើសសម្រាប់ការបន្សាំ | កិច្ចសហប្រតិបត្តិការដ៏មានសក្ដានុពល |
|---|---|---|
| ក្មេងៗដែលឪពុកម្ដាយចំណាកស្រុកដោយសារបញ្ហាអាកាសធាតុបណ្ដាលអោយមានបញ្ហាអសន្តិសុខស្បៀង, មិនបានទៅសាលារៀនពីព្រោះតែកាតព្វកិច្ចចំពោះជីវភាពគ្រួសារនិងបន្ទាប់មកការរៀនសូត្រធ្លាក់ចុះ និងមានអារម្មណ៍អៀនលែងចង់ទៅសាលារៀន។ | ក្រុមស្វ័យសិក្សាឬក្លិបសិក្សាពេលល្ងាច-នៅក្នុងផ្ទះមេភូមិ,ទីតាំងសាលារបស់អង្គការផ្ទះទឹកដូងឬសាលារៀនរដ្ឋ។ សុវត្ថិភាពរបស់កុមារនិងសាលារៀនត្រូវតែធ្វើការពិចារណា។ កុមារប្រហែលជាមានទំនុកចិត្តក្នុងការរៀនពីសិស្សដទៃ ឬក៏រៀនពីសិស្សសកលវិទ្យាជាជាងរៀនពីគ្រូ។ | មន្ទីរអប់រំយុវជននិងកីឡា៖ អាចប្រើប្រាស់សាលាបានក្រោយពីម៉ោងសិក្សាបានបញ្ចប់, អាចទំនាក់ទំនងជាមួយគ្រូបង្រៀនក្រោយពីម៉ោងសិក្សាធម្មតា<br>អង្គការផ្ទះទឹកដូង៖ អាចប្រើប្រាស់ទីតាំងសាលាក្រោយពីម៉ោងសិក្សា<br>ប៉ូលីសនិងក្រុមប្រឹក្សាឃុំ៖ សុវត្ថិភាព<br>សកលវិទ្យាល័យបាត់ដំបង៖ និស្សិតអាចជួយគាំទ្រការបង្រៀននិងសំណើរក្រុមស្វ័យសិក្សាឬក្លិបសិក្សា |
| អសន្តិសុខស្បៀងនាំអោយមានបញ្ហាកង្វះអាហាររូបត្ថម្ភ( ផ្ទះខ្លះខ្វះទឹកសម្រាប់សួនដំណាំនៅផ្ទះនិងសម្រាប់ធ្វើជីកំប៉ុស្ដ៍) | សួនដំណាំសហគមន៏- ចំណុចនេះគួរតែត្រូវបានធ្វើនៅទីសាធារណៈនិងទីធ្លាសាលារបស់អង្គការផ្ទះទឹកដូង ប៉ុន្តែត្រូវមានអ្នកថែរក្សាកំឡុងពេលថ្នាក់ឈប់សំរាករបស់សាលារៀន, គួរតែភ្ជាប់យុវជនទៅនិងចំណុចនេះនិងធ្វើការពិចារណាក្នុងការផ្ដល់វគ្គបណ្ដុះបណ្ដាលពីទឹកស្អាតនិងការគ្រប់គ្រងដី។ | មន្ទីរកសិកម្ម៖ ការអប់រំយុវជនពីការគ្រប់គ្រងទឹកនិងដី(កម្មវិធីដែលមានស្រាប់)<br>អង្គការផ្ទះទឹកដូង/អង្គការក្រៅរដ្ឋាភិបាល/មន្ទីរបរិស្ថាន៖ បណ្ដុះបណ្ដាលទៅលើបច្ចេកទេសនៃការអភិវឌ្ឍន៏ប្រព័ន្ធបរិស្ថានកសិកម្ម, ការអាចទទួលបាននូវទីតាំងសម្រាប់សួនដំណាំ, អណ្ដូងទឹកនៅក្នុងទីធ្លាសាលា |
| កង្វះទឹកស្អាតនៅគេហដ្ឋាន, កង្វះនៅការវិនិយោគចំពោះការដោះស្រាយបញ្ហាទាំងនេះនៅក្នុងសំណើរផែនការវិនិយោគឃុំ | អណ្ដូងទឹកនិងបង្គន់នៅផ្ទះ<br>ការតបណ្ដាញទឹករដ្ឋ(២០០ផ្ទះ)<br>ឧបករណ៍/សំភារៈស្ដុបទឹកទុកនៅរដូវប្រាំង | ឃុំ-បន្តនូវគំនិតនៃការចំណាយទៅលើការវិនិយោគលើប័ណ្ណក្រីក្រ<br>អង្គការក្រៅរដ្ឋាភិបាល-ត្រូវការម្ចាស់ជំនួយដើម្បីដោះស្រាយចំពោះផ្ទះនានាដែលនៅសល់ |

**កំរិតជីវភាពនិងបរិស្ថាន**

បញ្ហាដែលបានពិភាក្សារួមមាន៖

- ត្រូវការបន្តនូវកសិកម្មខ្នាតតូចដើម្បីកាត់បន្ថយការចំណាយទៅលើម្ហូបអាហារ។
- មានតែ៣០%ប៉ុណ្ណោះនៃភូមិចំការសំរោង១និង២ដែលបច្ចុប្បន្នប្រជាជនធ្វើកសិកម្ម។ បំណុលចំពោះស្ថាប័នមីក្រូហិរញ្ញវត្ថុមានន័យថាពាក់កណ្តាលនៃដីទាំងអស់នេះត្រូវបានគ្រប់គ្រង ហើយដីផ្សេងទៀតត្រូវជួល។
- កង្វះនៅប្រព័ន្ធស្រោចស្រពដោយសារតែរដូវប្រាំង, តម្លៃនៃអគ្គិសនី, កង្វះកម្លាំងពលកម្មនិងតម្លៃស្រូវទាបធ្វើអោយអ្នកធ្វើកសិកម្មមានជីវភាពក្រីក្រ, ប្រជាជនប្រហែលជាគ្មានជម្រើសដូចនេះត្រូវតែលក់ដីរបស់ពួកគាត់។
- កសិកម្មដែលនៅជិតក្រុងគឺមានសារៈសំខាន់ប៉ុន្តែប្រជាជននឹងមិនធ្វើវាឡើយនៅពេលដែលពួកគេអាចរកប្រាក់បាន៥ដុល្លារក្នុងមួយថ្ងៃតាមរយៈការធ្វើសំណង់។
- ប្រជាជនមានជីវភាពក្រីក្រ បើសិនជាពួកគាត់មិនទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការរៀនពួកគាត់នឹងមិនទៅរៀនពីបច្ចេកទេសកសិកម្មជាមួយមន្ទីរកសិកម្មនោះទេ-បើមានការបណ្តុះបណ្តាលសម្រាប់មនុស្ស៥នាក់ ប្រហែលជាមានតែ២ឬ៣នាក់ប៉ុណ្ណោះដែលនឹងចូលរួមរៀន។
- ប្រជាជនចាប់អារម្មណ៍ក្នុងការផលិតជីកំប៉ុសដើម្បីធ្វើអោយសំណើមនិងជីវជាតិដីល្អប្រសើរឡើង- សកលវិទ្យាល័យបាត់ដំបងមានបច្ចេកទេសថ្មីក្នុងការផលិតជីនេះដែលចំណាយពេលតែ២សប្តាហ៍ប៉ុណ្ណោះ។
- គម្រោងអាសស្ពាយ‘Aspire’របស់មន្ទីរកសិកម្មបានចាប់ផ្តើមក្នុងស្រុកចំនួន៣ក្នុងខេត្តបាត់ដំបង វាមានរយៈពេល២ឆ្នាំហើយនិងប្រហែលជាមកដល់ឃុំចំការសំរោងនេះនៅថ្ងៃអនាគត។ គម្រោងនេះជាប់ពាក់ព័ន្ធនិងការបណ្តុះបណ្តាលកសិករគំរូ ហើយអោយពួកគាត់ទៅបណ្តុះបណ្តាលបន្តទៅអ្នកផ្សេងទៀតអំពីជី សត្វល្អិត ប្រព័ន្ធស្រោចស្រព ការគ្រប់គ្រងដីនិងត្រី/ការចិញ្ចឹមមាន់។
- តំបន់នេះគឺល្អសម្រាប់ដំណាំហូបផ្លែប៉ុន្តែវាខ្វះនៅការសម្របសម្រួលដើម្បីជៀសវៀងចំនួនផលិតច្រើនហួសពេក និងតម្លៃថោកនៅទីផ្សារ។
- កម្រិតខ្ពស់នៃការប្រើប្រាស់ជីនិងថ្នាំសម្លាប់សត្វល្អិត បណ្តាលអោយមានការបំពុលទឹកដែលនាំអោយទិន្នផលនៃការដាំដុះបន្លែមានការថយចុះនិងមានផលប៉ះពាល់សម្រាប់សុខភាពចំពោះចំណីអាហារដែលបានផលិតឡើង។

ជម្រើសសម្រាប់ការបន្សាំដ៏មានសក្តានុពលដែលត្រូវបានកំណត់រួមមាន៖

| បញ្ហា | ជម្រើសសម្រាប់ការបន្សាំ | កិច្ចសហប្រតិបត្តិការដ៏មានសក្តានុពល |
|---|---|---|
| ត្រូវការរៀនពីបច្ចេកទេសកសិកម្មដែលធន់ឬរ័យឆ្លាតនឹងអាកាសធាតុប៉ុន្តែជាមួយនិងផលប៉ះពាល់ដែលបានកំណត់ទៅលើពេលវេលារបស់កសិករ | បច្ចេកទេសកសិកម្មថ្មី៖ សាលាស្រែកសិករពី១ទៅ២ម៉ោងក្នុងមួយថ្ងៃ, ដើម្បីជៀសវាងការចំណាយលើឱកាស ការកំណត់គោលដៅ “ការបណ្តុះបណ្តាលគ្រូបង្គោល” ជាមួយកសិករល្អបច្ចេកទេសធ្វើជីកំប៉ុសសរីរាង្គនិងការសន្សំសំចៃទឹក | បុគ្គលិកសកលវិទ្យាល័យបាត់ដំបងនិងនិស្សិតអាចជួយក្នុងការបង្រៀនបច្ចេកទេសថ្មីនេះ មន្ទីរកសិកម្មនិងឃុំអាចជួយគាំទ្រនូវបច្ចេកទេសថ្មីពីព្រោះតែវាមានការចំណាយតិច ដែលអាចប្រើប្រាស់សាលាជាទីតាំងសម្រាប់ការជួបជុំ។ |
| ត្រូវការស្វែងរកដំណាំផ្សេងទៀតជំនួសស្រូវនិងសម្របសម្រួលដំណាំផ្សេងៗទៀតដើម្បីធានាតម្លៃស្រូវល្អ | សហគមន៍កសិកម្ម[1] (AC) ធ្វើការពិភាក្សាពីអ្វីដែលគួរដាំនិងពេលណាហើយថាតើពួកគេអាចជាផ្នែកមួយនៃកិច្ចសន្យាកសិកម្មដែរឬទេហើយនិងធ្វើការបង្កើត”ធានាគារស្រូវ”<br><br>តែផ្សំពីរុក្ខជាតិគឺជាសហគ្រាសខ្នាតតូចផ្សេងទៀត ដែលមិនត្រូវការទឹកច្រើនសម្រាប់ការដាំដុះនិងមិនត្រូវការទីតាំងដីធំ ប៉ុន្តែវាត្រូវការនូវការបណ្តុះបណ្តាលចំពោះបច្ចេកទេសកសិកម្មសរីរាង្គ | មន្ទីរកសិកម្ម/សកលវិទ្យាល័យបាត់ដំបងអាចធ្វើការអភិវឌ្ឍន៍និងបណ្តុះបណ្តាលសហគមន៍អំពីសហគមន៏កសិកម្ម<br>អង្គការក្រៅរដ្ឋាភិបាលផ្តល់នូវការចាប់ផ្តើមសម្រាប់សហគមន៏កសិកម្ម<br>អង្គការផ្ទះទឹកដូងអាចចាប់ផ្តើមធ្វើការសាកល្បងនិងចរចារជាមួយអ្នកទិញជនជាតិជប៉ុននិងដើម្បីធ្វើអោយប្រសើរឡើងនូវការបណ្តុះបណ្តាល។ សកលវិទ្យាល័យអាចផ្តល់នូវទីតាំងទីពីរសម្រាប់ការសាកល្បង។ហើយអាចធ្វើការពង្រីកទៅផ្ទៃដីឯងជនផ្សេងទៀតបើសិនជាជោគជ័យ។ |

[1] This is the Khmer term for agricultural co-operative; co-operative is not used because of obvious historical links to Khmer Rouge regime.

## ការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ

អាកាសធាតុត្រូវបានកត់សម្គាល់ថាមានការប្រែប្រួលតាំងពី២០ឆ្នាំមុន។ រដូវវស្សាមកដល់យឺត ហើយខ្លាំងនិងមានរយៈពេលខ្លីហើយនិងភ្លៀងមូសុងដើមរដូវជាទូទៅគឺមានតិច។ ការប្រែប្រួលទាំងអស់នេះគឺមានន័យថាមានទឹកជំនន់ច្រើនជាងមុន, រដូវដាំដុះស្រូវមានរយៈពេលខ្លីជាងមុនហើយមានការរាំងស្ងួតរយៈពេលយូរនិងញឹកញាប់។ ការផ្លាស់ប្តូរទាំងអស់នេះនិងត្រូវបានលើកឡើងក្នុងអំឡុងពេលការងារដំបូងរបស់យើង។

បញ្ហាដែលបានពិភាក្សារួមមាន៖

- អាកាសធាតុមានការប្រែប្រួលយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំនិងពីកន្លែងមួយទៅកន្លែងមួយ។ ឆ្នាំមុនភ្លៀងធ្លាក់ដើមឆ្នាំបន្ទាប់មកមិនមានភ្លៀង ហើយបន្ទាប់មកភ្លៀង។ ជាឧទាហរណ៍ កាលពីចុងសប្តាហ៍ភ្លៀងធ្លាក់នៅទំនប់កំពីងពួយមានកម្រិត១០០មីលីលីត្រប៉ុន្តែនៅវាលស្រែមិនមានភ្លៀងនោះទេ។
- ការព្យាករណ៍ពីអាកាសធាតុបានអោយដឹងមុនពី១ទៅ២សប្តាហ៍តាមរយៈទូរទស្សន៍និងវិទ្យុ។ទោះជាយ៉ាងណាក៏ដោយការព្យាករណ៍សម្រាប់រយៈពេលវែងនៅមានកម្រិតនៅឡើយ។
- មន្ទីរកសិកម្មត្រូវប្រាកដជាមួយនិងការព្យាករណ៍អំពីភ្លៀងដើម្បីជៀសវាងការអនុវត្តខុស។ កាលពី២ឆ្នាំមុន មន្ទីរកសិកម្ម បានព្រមានអំពីកម្រិតតិចនៃទឹកភ្លៀង តែជាសំណាងល្អរបស់កសិករគឺភ្លៀងធ្លាក់មានកម្រិតច្រើនជាងការរំពឹងទុក។ ទោះជាយ៉ាងណាក៏ដោយ ឆ្នាំមុនមន្ទីរកសិកម្មបានព្យាករណ៍ពីគ្រោះរាំងស្ងួតនិងបានជម្រាបជូនដល់កសិករអោយធ្វើការដាំដុះត្រឹមតែ១០,០០០ហិចតាប៉ុណ្ណោះក្នុងខេត្ត តែកសិករបានធ្វើរហូតដល់៣០,០០០ហិចតា ដូចនេះការដាំដុះនេះគឺបរាជ័យ។
- ឆ្នាំនេះការព្យាករណ៍គឺមានភ្លៀងធ្លាក់ខ្លាំងនៅចុងខែកញ្ញាប៉ុន្តែមានភ្លៀងតិចនៅពាក់កណ្តាលខែតុលាដែលជាពេលវេលាត្រូវការទឹកសមាប្រស្រូវ។ ការព្យាករណ៍នេះមិនបានដោះស្រាយការប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយនោះទេ។

ជម្រើសសម្រាប់ការបន្សាំដ៏មានសក្តានុពលដែលត្រូវបានកំណត់រួមមាន៖

| បញ្ហា | ជម្រើសសម្រាប់ការបន្សាំ | កិច្ចសហប្រតិបត្តិការដ៏មានសក្តានុពល |
|---|---|---|
| តម្រូវអោយមានការយល់ដឹងអោយកាន់តែល្អប្រសើរឡើងចំពោះការកើនឡើងនៃការប្រែប្រួលអាកាសធាតុ | បញ្ចូលការយល់ដឹងពីការប្រែប្រួលអាកាសធាតុទៅក្នុងការបណ្តុះបណ្តាលទាំងអស់ និងវិធានការសាមញ្ញដូចជាដាំដំណាំមានបុរេក់ ដំបូលដើម្បីកាត់បន្ថយកំដៅ | សកលវិទ្យាល័យបាត់ដំបង/មន្ទីរកសិកម្ម/អង្គការផ្ទះទឹកដូង/មន្ទីរអប់រំយុវជននិងកីឡា |
| ត្រូវការនូវការគ្រប់គ្រងគ្រោះមហន្តរាយអោយបានល្អប្រសើរឡើងដើម្បីជៀសវៀងនូវផលប៉ះពាល់ពីគ្រោះទឹកជំនន់/រាំងស្ងួត | ផ្សព្វផ្សាយពីការរក្សាទឹកនិងស្បៀងទុកសម្រាប់ពេលគ្រោះមហន្តរាយនិងផ្តល់នូវធុង និងអណ្តូងទឹកសម្រាប់បញ្ហានេះ | អង្គការក្រៅរដ្ឋាភិបាល/មន្ទីរកសិកម្ម/មន្ទីរអភិវឌ្ឍន៍ជនបទ/ផែនការវិនិយោគឃុំ |

# APPENDIX 1:

## TOOLS TO SUPPORT COMMUNITY RESILIENCE ASSESSMENT

Many rural communities in poorer countries are yet to be exposed to the concepts of vulnerability, adaptive capacity or climate adaptation planning, despite having direct experience of the impacts of changing climate. These communities may or may not have had exposure to participatory rural appraisal and other community development techniques. Others have been engaged directly in vulnerability, adaptive capacity, disaster or resilience assessments.

We included the following tools in Cambodian case studies to (i) introduce the project gently with communities and start a discussion about climate change, (ii) provide a context for the community resilience assessment, and (iii) provoke thinking about community priorities.

The tools were derived from the Care CVCA handbook (http://careclimatechange.org/tool-kits/cvca/), an FAO adaptation of this, and tools developed by University of the South Pacific's Pacific Centre for Environment and Sustainable Development (http://careclimatechange.org/tool-kits/cvca/).

## TOOL 1: HISTORICAL TIMELINE

This exercise provides information about climate hazards in the community and a community's sensitivity to them. It is helpful in initiating discussion about climate change, and should be used before the resilience analysis to provide background discussion.

***Instructions***

Draw the table on a large sheet of paper

Explain to participants:

*This exercise involves thinking about key events that have happened in your village. It will help to understand whether your responses to them are changing. We will then ask you some questions about the timeline. Let me give you an example first, then you can provide examples*

| Year | Event / duration | Impact - social, economic and ecological |
|---|---|---|
| 2012 | Flood - lasted 2 weeks | Schools close<br>Damage to roads - it's still not fixed and its more difficult on a bike now<br>Rotten crops - had to buy food from Thailand at high cost, and it was bad quality |
| 2016 | | |
| 2015 | | |
| 2014 | | |
| 2013 | | |
| 2012 | | |
| 2011 | | |
| 2010 | | |
| 2009 | | |
| 2008 | | |
| 2007 | | |
| 2006 | | |
| 2005 | | |
| 2004 | | |
| 2003 | | |
| 2002 | | |
| 2001 | | |
| 2000 | | |

# TOOL 2: HAZARD IMPACT AND COPING STRATEGIES

This exercise provides information about a community's sensitivity to climate hazards and adaptive capacity. It is helpful in initiating discussion about adaptation options, and could be used either before the resilience analysis or after it.

***Instructions***

Draw the table on a large sheet of paper

Explain to participants:

*This exercise involves thinking about how you manage climate impacts, and whether your responses to them are changing. Let me give you an example first, then you can provide examples*
*We will then discuss some of the community's adaptive capacity towards reducing impact sensitivity.*

| Type of hazard | How many times since 2000? | Impacts (1 is low, 5 is high) and change (increasing, decreasing) | What coping strategies are used? Are they effective? (1 is low, 5 is high), why/why not |
|---|---|---|---|
| *Flood* | *Every year* | *3 - decreasing since 2000* | *Houses on stilts5 - keep people safe*<br>*Save food for winter 2 - not enough money to buy food* |
| Cyclone | | | |
| Drought | | | |
| Disease | | | |
| ......... | | | |
| | | | |
| | | | |

Use the timeline table to identify these

Potential discussion questions (if time allows)

1. Were men and women affected differently by these hazards? Any examples? (health, diet, drop out of school, migration to find other work, etc.)
2. Do you have traditional knowledge you use for adaptation (e.g. start planting rice after it has been humid at night for 3 weeks)?
3. What events do you expect/suppose will occur in the future? Will they be like they are now or will they be different? If different, how different?
4. Does your idea of future events affect the way you do things now? If so, how?
5. Does the community believe they have the skills and resources to adapt to the changing environment? If not, what do they need to be able to adapt?

# TOOL 3: NEEDS PRIORITISATION

This exercise provides information about a community's development priorities, based on sensitivity to climate hazards. It can then be contrasted against annual planning priorities. In combination, this will help to uncover perceptions about the role of different groups in development, and whom might address emerging climate adaptation priorities. It should be used before or as part of the resilience analysis.

The tool has four parts:

1. Needs ranking
2. Sensitivity to climate impacts
3. Vulnerability ranking
4. Funding ranking
5. Comparison

If the tool is run as part of the resilience assessment, the first item in part D should be completed beforehand.

This tool was adapted from the University of the South Pacific's Integrated Climate change and Disaster Risks Community Planning Toolkit.

## 1. COMMUNITY DEVELOPMENT NEEDS

Ask the participants to list the community development needs/items and write them in the first column and the top row, in order. Each item across the row is then compared to each item down the column. Ask the participants which of the two is more important for their community. Once an item has been identified as being more important than the other that item is to be written in the empty box where the column and row meet. Note that the example excludes electricity, because there was none in this community.

| | Drinking water | Health centre | Education | Agriculture skills | Roads | Irrigation |
|---|---|---|---|---|---|---|
| **Drinking water** | | Drinking water | Drinking water | Drinking water | Drinking water | Irrigation |
| **Health care** | | | Health care | Health care | Health care | Health care |
| **Education** | | | | Agriculture skills | Education | Irrigation |
| **Agriculture Skills** | | | | | Agriculture skills | Irrigation |
| **Roads** | | | | | | Irrigation |
| **Irrigation** | | | | | | |

For example:

After the table has been completed, count the number of appearances, and rank the needs from most common (a rank of 1) to least common. This becomes the Need ranking.

## 2. SENSITIVITY TO CLIMATE IMPACTS

Draw the table below and then explain to participants:

*Now that we know about which things are more important than others. We are now going to ask you about how you have access to them in normal times and in times of hazards.*

*Rate access on a score of 1-5 during normal times, and a score of 1-5 during times of climate hazards such as flood, drought or storm (5 means **very in-accessible**, 1 means **very accessible**).*

| Item | Normal access | Access during hazards |
|---|---|---|
| Drinking water | 3 | 4 |
| Health care | 2 | 3 |
| Education | 1 | 3 |
| Agricultural skills | 4 | 4 |
| Roads | 3 | 2 |
| Irrigation | 5 | 5 |

## 3. VULNERABILITY RANKING

This can be conducted independently of the community (e.g. during a workshop break)

Fill in the scores from parts A & B. Compile an overall score for each by multiplying columns 2, 3 and 4. Prioritise the scores by ranking them from highest to lowest score. A higher priority means that more resources should be devoted to this activity rather than anything else.

| Item | Need ranking (Part 1) | Normal access (Part 2) | Hazard access (Part 2) | Score | Vulnerability ranking |
|---|---|---|---|---|---|
| Drinking water | 4 | 3 | 4 | 48 | 2 |
| Health care | 4 | 2 | 3 | 24 | 4 |
| Education | 1 | 2 | 3 | 6 | 5 |
| Agricultural skills | 2 | 4 | 4 | 32 | 3 |
| Road | 0 | 3 | 2 | 0 | 6 |
| Irrigation | 4 | 5 | 5 | 100 | 1 |

Based on this chart, priorities are ranked highest to lowest fromIrrigation, Drinking water, etc.

## 4. FUNDING PRIORITIES

This part can be completed independently of the community

First, group the funding from the relevant annual plan (e.g. Commune Investment Plan) under the needs identified in part 1. Next, identify the rank based on highest to lowest budget. See the end notes about presenting actual figures to the group.

| Item | Percentage budget | Plan rank |
|---|---|---|
| Drinking water | 1.3% | 8 |
| Healthcare | 4.0% | 7 |
| Education | 16.3% | 2 |
| Agriculture and skills | 6.5% | 4 |
| Irrigation | 5.7% | 6 |
| Roads | 13.9% | 3 |
| Natural Environment | 5.8% | 5 |
| Administration | 46.4% | 1 |

## 5. COMPARING RANKINGS

Next, compare ranks. The Plan Rank come from part 4, the *Vulnerability Rank* comes from the last column of Part 3 (climate vulnerability priorities) and the *Need Rank* comes from Part 1.

| Item | Plan rank | Need rank | Vulnerability rank |
|---|---|---|---|
| Irrigation | 5 | 3 | 1 |
| Drinking water | 7 | 1 | 2 |
| Agricultural skills | 3 | 3 | 3 |
| Healthcare | 6 | 2 | 4 |
| Education | 1 | 1 | 5 |
| Road | 2 | 3 | 6 |
| Natural environment | 4 | 0 | 0 |

You are now ready for discussion with the group about why the ranks differ:

i. Why do plan, Need and Vulnerability rank differ? Does cost explain the Plan Rank of some things?
For example, the cost of irrigation may make it a high plan rank (it is expensive) or a low plan rank (it is too expensive).

ii. Compare Plan and Vulnerability Rank. Do some things gain less funds than they should based on need? Why? Whose responsibility is it to provide these things? How are those funders identified? What happens if that funding does not exist or is in decline?

For example, Drinking water receives a low Plan rank but a high Vulnerability Rank. This might be explained because NGOs have provided drinking water wells in the past. The commune needs to consider if the NGOs will continue to meet this need.

iii. What things are more important if climate gets worse and why (the Vulnerability Rank column)? Can these be addressed in existing funding requests? Should these be addressed by donors? If so, how?
For example, for Irrigation Vulnerability Rank is high but Plan Rank is low, because private companies are expected to undertake this development. The commune needs to be sure they are aware of how important this priority is, especially given climate change.

**Note: Limitations to discussions**

Discussions about priorities can be difficult because of concerns about corruption. Sometimes, what is funded depends on National, Provincial and District priorities. Sometimes, plans are developed out of order, so needs do not align. Sometimes priorities and needs change after plans are developed (for example, because of a disaster or because of improved services). Sometimes, commune councils or groups may not be aware of budgets. Sometimes, a budget in a plan may not actually exist in reality. We focus on priorities, not actual budgets, to avoid some of these discussions.

Mismatched priorities require careful consideration of both causes and consequences, and highlight the complexity of planning; budget for priority needs may never be met by government. One means to address this may be to develop a process for regularly updating priorities, and for sharing these directly and on a regular basis with aid agencies, providing a more integrated approach to community development. This is shown in the figure below, where the circle represents the planning process, N represents national priorities, P represents provincial priorities, D represents district priorities, and C represents commune priorities.



# ឧបសម្ព័ន្ធ១៖

## ឧបករណ៍ដើម្បីគាំទ្រដល់ការវង្វាយតម្លៃភាពធន់របស់សហគមន៍

សហគមន៍ជនបទជាច្រើននៅក្នុងប្រទេសក្រីក្រមិនទាន់បានទទួលគំនិតស្តីពីការប៉ះពាល់ទៅនឹងភាពងាយរងគ្រោះ, សមត្ថភាពក្នុងការបន្សាំ ឬផែនការបន្សាំនិងអាកាសធាតុ បើទោះបីជាធ្លាប់ទទួលបានបទពិសោធន៍ពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុដោយផ្ទាល់ក៏ដោយ។ សហគមន៍ទាំងនេះប្រហែលជាអាចឬមិនអាចទទួលការប៉ះពាល់ពីការវាយតម្លៃជនបទដោយមានការចូលរួម និងបច្ចេកទេសក្នុងការអភិវឌ្ឍន៍សហគមន៍ផ្សេងទៀតទេ។ អ្នកផ្សេងទៀតត្រូវបានចូលរួមដោយផ្ទាល់ក្នុងការវង្វាយតម្លៃ ភាពងាយរងគ្រោះ, សមត្ថភាពក្នុងការបន្សាំ, គ្រោះមហន្តរាយឬភាពធន់។

ពួកយើងបានរួមបញ្ចូលនូវឧបករណ៍ដូចខាងក្រោម  សម្រាប់ករណីសិក្សានូវប្រទេសកម្ពុជាដើម្បីធ្វើ (i) ការណែនាំគម្រោងជាមួយសហគមន៍និងចាប់ផ្តើមធ្វើការពិភាក្សាអំពីបម្រែបម្រួលអាកាសធាតុ(ii) ផ្តល់នូវបរិបទសម្រាប់ការវង្វាយតម្លៃភាពធន់របស់ សហគមន៍ និង(iii)បំផុសនូវការគិតអំពីចំណុចអាទិភាពសម្រាប់សហគមន៍។

ឧបករណ៍ត្រូវបានទាញយកមកពីសៀវភៅឃែ ស៊ីវីស៊ីអេ (http://careclimatechange.org/tool-kits/cvca/),ការបន្សាំរបស់អង្គការអេសហ្វ អេ អូFAOនិងឧបករណ៍ដែលធ្វើអោយប្រសើរឡើងដោយមជ្ឈមណ្ឌលប៉ាស៊ីភិចសម្រាប់បរិស្ថាន និងការអភិវឌ្ឍន៍ដោយនិរន្តភាពរបស់សកលវិទ្យាល័យសៅប៉ាស៊ីភិច(http://careclimatechange.org/tool-kits/cvca/)។

## ឧបករណ៍ទី១ ៖ ពេលវេលាជាប្រវត្តិ

លំហាត់នេះផ្តល់ព័ត៌មានអំពីបាតុភូតធម្មជាតិនៅក្នុងសហគមន៍និងភាពប្រែប្រួលរបស់សហគមន៍។ វាជួយក្នុងការចាប់ផ្តើម នូវកិច្ចពិភាក្សាអំពីបម្រែបម្រួលអាកាសធាតុនិងគួរតែប្រើនៅមុនពេលការវិភាគភាពធន់ដើម្បីផ្តល់ជាពន្លឺសម្រាប់ការពិភាក្សា។

***ការណែនាំ***

គូរតារាងនៅលើក្រដាសធំមួយ

ពន្យល់ទៅដល់អ្នកចូលរួមៈ

*លំហាត់នេះជាប់ពាក់ព័ន្ធនិងការគិតអំពីព្រឹត្តិការណ៍សំខាន់ដែលកើតឡើងនៅក្នុងភូមិរបស់អ្នក។វានិងជួយអោយយល់ដឹងថា តើការឆ្លើយតបរបស់អ្នកចំពោះពួកគេផ្លាស់ប្តូរឬអត់។ បន្ទាប់មកពួកយើងនឹងសួរអ្នកនូវសំណួរអំពីពេលវេលាដែលកើតពីពេលមុន។ ខ្ញុំសូមផ្តល់អោយអ្នកនូវឧទាហរណ៍មុន បន្ទាប់មកអ្នកអោយឧទាហរណ៍វិញម្តង។*

| ឆ្នាំ | ព្រឹត្តិការណ៍/ រយៈពេល | ផលប៉ះពាល់– សង្គម, សេដ្ឋកិច្ចនិងបរិស្ថាន |
|---|---|---|
| ២០១២ | ទឹកជំនន់ – អូសបន្លាយ<br>រយៈពេល២សប្តាហ៍ | សាលារៀនបិទ<br>បំផ្លាញផ្លូវ–វានៅតែមិនទាន់បានជួសជុលនិងវាធ្វើអោយការធ្វើដំណើរកាន់តែលំបាក<br>ដំណាំរលួយ – ត្រូវទិញម្ហូបពីប្រទេសថៃក្នុងតម្លៃថ្លៃនិងគុណភាពមិនល្អ |
| ២០១៦ | | |
| ២០១៥ | | |
| ២០១៤ | | |
| ២០១៣ | | |
| ២០១២ | | |
| ២០១១ | | |
| ២០១០ | | |
| ២០០៩ | | |
| ២០០៨ | | |
| ២០០៧ | | |
| ២០០៦ | | |
| ២០០៥ | | |
| ២០០៤ | | |
| ២០០៣ | | |
| ២០០២ | | |
| ២០០១ | | |
| ២០០០ | | |

## ឧបករណ៍ទី២ ៖ ផលប៉ះពាល់ពីបាតុភូតនិងយុទ្ធសាស្រ្តដោះស្រាយ

លំហាត់នេះផ្តល់នូវព័ត៌មានអំពីការប្រែប្រួលរបស់សហគមន៍ទៅនិងបាតុភូតធម្មជាតិនិងសមត្ថភាពនៃការបន្សាំ។ វាជួយនៅក្នុងការចាប់ផ្តើមការពិភាក្សាអំពីជម្រើសសម្រាប់ការបន្សាំនិងអាចប្រើមុនឬក្រោយការវិភាគភាពធន់។

***ការណែនាំ***

គូរតារាងនៅលើក្រដាសធំមួយ

ពន្យល់ទៅដល់អ្នកចូលរួម:

*លំហាត់នេះជាប់ពាក់ព័ន្ធនិងការគិតអំពីរបៀបដែលអ្នកគ្រប់គ្រងផលប៉ះពាល់នៃអាកាសធាតុនិងថាតើការឆ្លើយតបរបស់អ្នកចំពោះពួកគេផ្លាស់ប្តូរឬអត់។ខ្ញុំសូមផ្តល់អោយអ្នកនូវឧទាហរណ៍មុន បន្ទាប់មកអ្នកអោយឧទាហរណ៍វិញម្តង។*
*បន្ទាប់មកពួកយើងពិភាក្សាអំពីសមត្ថភាពក្នុងការបន្សាំរបស់សហគមន៍ឆ្ពោះទៅរកការកាត់បន្ថយភាពប្រែប្រួលនៃផលប៉ះពាល់។*

| ប្រភេទនៃបាតុភូត | កើតឡើងប៉ុន្មានដងហើយតាំងពីឆ្នាំ២០០០? | ផលប៉ះពាល់(១គឺទាប, ៥គឺខ្ពស់) ការប្រែប្រួល(កើនឡើង, ធ្លាក់ចុះ) | តើយុទ្ធសាស្រ្តអ្វីដែលបានប្រើដើម្បីដោះស្រាយ? តើវាមានប្រសិទ្ធិភាពដែរឬទេ?ផលប៉ះពាល់(១គឺទាប, ៥គឺខ្ពស់) ហេតុអ្វី/ហេតុអ្វីមិន |
|---|---|---|---|
| *ទឹកជំនន់* | *រៀងរាល់ឆ្នាំ* | *៣ – ធ្លាក់ចុះចាប់តាំងពីឆ្នាំ២០០០* | *ផ្ទះមានជើងសសរ ៥ – រក្សាមនុស្សអោយមានសុវត្ថិភាព រក្សាម្ហូបទុកសម្រាប់រដូវគ្រជាក់ ២– ថវិការមិនគ្រប់គ្រាន់សម្រាប់ទិញម្ហូប* |
| ព្យុះ | | | |
| រាំងស្ងួត | | | |
| ជំងឺ | | | |
| ......... | | | |
| | | | |
| | | | |

ប្រើតារាងពេលវេលាពីពេលមុនដើម្បីកំណត់ចំណុចទាំងនេះ

សំណួរសម្រាប់ពិភាក្សាដ៏មានសក្តានុពល(បើសិនជាពេលវេលាអនុញ្ញាតិ)

១. តើស្ត្រីនិងបុរសរងផលប៉ះពាល់ពីបាតុភូតធម្មជាតិខុសគ្នាដែរឬទេ? មានឧទាហរណ៍? (សុខភាព, តមអាហារ, ឈប់រៀន, ចំណាកស្រុកដើម្បីធ្វើការ...)
២. តើមានចំណេះដឹងបែបប្រពៃណីដែលអ្នកប្រើសម្រាប់ការបន្សាំដែរឬទេ? (ឧទា. ចាប់ផ្តើមដាំស្រូវបន្ទាប់ពីវាបានសើមនៅពេលយប់រយៈពេល៣សប្តាហ៍)?
៣. តើព្រឹត្តិការណ៍អ្វីដែលអ្នករំពឹងថាវានឹងកើតឡើងនៅថ្ងៃអនាគត? តើវានឹងដូចពេលបច្ចុប្បន្នឬខុសប្លែកគ្នា? បើសិនជាវាប្លែក តើប្លែកយ៉ាងមិចដែរ?
៤. តើគំនិតរបស់អ្នកអំពីព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅថ្ងៃអនាគតនឹងប៉ះពាល់ដល់អ្វីដែលអ្នកកំពុងធ្វើដែលឬទេ? បើសិនជា ប៉ះពាល់ តើប៉ះពាល់យ៉ាងដូចម្តេច?
៥. តើសហគមន៍ជឿជាក់ថាពួកគេមានជំនាញនិងធនធានដើម្បីបន្សាំទៅនឹងការប្រែប្រួលបរិស្ថានដែរឬទេ? បើសិនជាមិនជឿតើអ្វីដែលពួកគេត្រូវការដើម្បីអោយពួកគេអាចបន្សាំបាន?

# ឧបករណ៍ទី៣ ៖ តម្រូវការជាអាទិភាព

លំហាត់នេះផ្តល់នូវព័ត៌មានអំពីការអភិវឌ្ឍន៍ជាអាទិភាពរបស់សហគមន៍ ដោយផ្អែកទៅលើការប្រែប្រួលនៃបាតុភូតធម្មជាតិ។ វាអាចមានការផ្ទុយគ្នាជាមួយផែនការជាអាទិភាពប្រចាំឆ្នាំ។ នៅក្នុងការរួមបញ្ចូលគ្នា ចំណុចនេះនឹងជួយដោះស្រាយ ទស្សនៈអំពីតួនាទីរបស់ក្រុមផ្សេងៗគ្នាក្នុងការអភិវឌ្ឍន៍, និងចំពោះអ្នកដែលប្រហែលនឹងជួយដោះស្រាយក្នុងការច្របាច់បញ្ចូលគ្នានូវ ជម្រើសជាអាទិភាពសម្រាប់ការបន្សាំ។ វាគួរតែប្រើមុនឬក៏ប្រើជាផ្នែកមួយនៃការវិភាគភាពធន់។

ឧបករណ៍នេះមានបួនផ្នែកៈ

១. ចំណាត់ថ្នាក់តម្រូវការ
២. ការប្រែប្រួលចំពោះផលប៉ះពាល់នៃអាកាសធាតុ
៣. ចំណាត់ថ្នាក់ភាពងាយរងគ្រោះ
៤. ចំណាត់ថ្នាក់មូលនិធិ
៥. ការប្រៀបធៀប

បើសិនជាឧបករណ៍នេះដើរតួនាទីជាផ្នែកមួយនៃរង្វាយតម្លៃភាពធន់ វត្ថុទីមួយគឺផ្នែក D ដែលគួរបំពេញទុកជាមុន។
ឧបករណ៍នេះបានប្រែប្រួលពីការប្រមូលផ្តុំឧបករណ៍ធ្វើផែនការសហគមន៍ចំពោះហានិភ័យគ្រោះមហន្តរាយនិងការបម្រែបម្រួលអាកាសធាតុ។

## ១. តម្រូវការការអភិវឌ្ឍន៍សហគមន៍

ស្នើរអ្នកចូលរួមអោយសរសេរចុះនូវតម្រូវការ/វត្ថុ និងសរសេរវានៅក្នុងតារាងជួរឈរទីមួយនិងជួរដេកខាងលើគេតាមលំដាប់។ ធាតុនីមួយៗនៃជួរដេកនិងត្រូវធ្វើការប្រៀបធៀបជាមួយនិងធាតុនីមួយៗនៃជួរឈរ។ សួរអ្នកចូលរួម ពីធាតុពីរយ៉ាងដែលមានសារៈសំខាន់ខ្លាំងសម្រាប់សហគមន៍របស់ពួកគេ។ នៅពេលដែលធាតុនោះត្រូវបានកំណត់ថាជាធាតុសំខាន់ជាងគេ ដែលត្រូវបានសរសេរក្នុងប្រអប់ទរទេរ វាជាកន្លែងដែលជួរឈរនិងជួរដេកជួបគ្នា។ ចំណាំថាឧទាហរណ៍មិនរាប់បញ្ចូលនូវភ្លើងអគ្គិសនី ពីព្រោះគ្មានអគ្គិសនីទេក្នុងសហគមន៍នេះ។

| | ទឹកបរិភោគ | មណ្ឌលសុខភាព | ការអប់រំ | ជំនាញកសិកម្ម | ផ្លូវ | ប្រព័ន្ធស្រោចស្រព |
|---|---|---|---|---|---|---|
| ទឹកបរិភោគ | | ទឹកបរិភោគ | ទឹកបរិភោគ | ទឹកបរិភោគ | ទឹកបរិភោគ | ប្រព័ន្ធស្រោចស្រព |
| ការថែទាំសុខភាព | | | ការថែទាំសុខភាព | ការថែទាំសុខភាព | ការថែទាំសុខភាព | ការថែទាំសុខភាព |
| ការអប់រំ | | | | ការអប់រំ | ការអប់រំ | ការអប់រំ |
| ជំនាញកសិកម្ម | | | | | ជំនាញកសិកម្ម | ប្រព័ន្ធស្រោចស្រព |
| ផ្លូវ | | | | | | ប្រព័ន្ធស្រោចស្រព |
| ប្រព័ន្ធស្រោចស្រព | | | | | | |

ជាឧទាហរណ៍:

ក្រោយពីតារាងត្រូវបានបំពេញ រាប់ចំនួនដែលបានបំពេញចូល និងចាត់ចំណាត់ថ្នាក់ពីចំណុចដែលជាតម្រូវការទូទៅខ្លាំង(ចំណាត់ថ្នាក់លេខ១) ទៅចំណុចដែលមិនមែនជាតម្រូវជាទូទៅ។ ការងារនេះគឺជាចំណាត់ថ្នាក់តម្រូវការ។

## ២. ការប្រែប្រួលចំពោះផលប៉ះពាល់នៃអាកាសធាតុ

គូរតារាងខាងក្រោមហើយបន្ទាប់មកពន្យល់ទៅដល់អ្នកចូលរួមៈ

ពេលនេះយើងដឹងថាចំណុចមួយណាដែលមានសារៈសំខាន់ជាងគេ។ ឥលូវនេះយើងនឹងសួរអ្នកថា តើអ្នកទទួលបាននូវចំណុចដែលមានសារៈសំខាន់ជាងគេដោយរបៀបណានៅពេលពេលធម្មតា និងនៅពេលមានបាតុភូតធម្មជាតិ។

ការដាក់ពិន្ទុពី១-៥កំឡុងពេលវេលាធម្មតា និងការដាក់ពិន្ទុ១-៥កំឡុងពេលវេលាបាតុភូតធម្មជាតិដូចជាទឹកជំនន់ រាំងស្ងួតនិងខ្យល់ព្យុះ (៥មានន័យថា ពិបាកទទួលបាន, ១មានន័យថាអាចទទួលបានដោយស្រួល)

| វត្ថុ | ការទទួលបានពេលធម្មតា | ការទទួលបានកំឡុងពេលបាតុភូត |
|---|---|---|
| ទឹកបរិភោគ | ៣ | ៤ |
| ការថែទាំសុខភាព | ២ | ៣ |
| ការអប់រំ | ១ | ៣ |
| ជំនាញកសិកម្ម | ៤ | ៤ |
| ផ្លូវ | ៣ | ២ |
| ប្រព័ន្ធស្រោចស្រព | ៥ | ៥ |

## ៣. ចំណាត់ថ្នាក់ភាពងាយរងគ្រោះ

កិច្ចការនេះអាចធ្វើបានដោយឯកភាជ្យរបស់សហគមន៍ (ឧទា.កំឡុងពេលសំរាករបស់សិក្ខាសាលា) បំពេញនូវពិន្ទុពីផ្នែក អេ&ប៊ី (A & B)។ ចងក្រងនូវពិន្ទុសរុបសម្រាប់ផ្នែកនីមួយៗដោយគុណជួរឈរ ២,៣និង៤។ ចាត់អាទិភាពពិន្ទុ ដោយចាត់ចំណាត់ថ្នាក់ពិន្ទុពីខ្ពស់បំផុតទៅទាបបំផុត។អាទិភាពដែលខ្ពស់ជាងគេមានន័យថាធនធានច្រើនគួរតែប្រើសម្រាប់សកម្មភាពនេះជាជាងសកម្មភាពផ្សេង។

| វត្ថុ | ចំណាត់ថ្នាក់តម្រូវការ(ផ្នែកទី១) | ការទទួលបានពេលធម្មតា(ផ្នែកទី២) | ការទទួលបានកំឡុងពេលបាតុភូត (ផ្នែកទី២) | ពិន្ទុ | ចំណាត់ថ្នាក់ភាពងាយរងគ្រោះ |
|---|---|---|---|---|---|
| ទឹកបរិភោគ | ៤ | ៣ | ៤ | ៤៨ | ២ |
| ការថែទាំសុខភាព | ៤ | ២ | ៣ | ២៤ | ៤ |
| ការអប់រំ | ១ | ២ | ៣ | ៦ | ៥ |
| ជំនាញកសិកម្ម | ២ | ៤ | ៤ | ៣២ | ៣ |
| ផ្លូវ | ០ | ៣ | ២ | ០ | ៦ |
| ប្រព័ន្ធស្រោចស្រព | ៤ | ៥ | ៥ | ១០០ | ១ |

ផ្អែកទៅលើតារាងទិន្នន័យ អាទិភាពគឺចាត់ចំណាត់ថ្នាក់ពីខ្ពស់បំផុតទៅទាបបំផុតពីប្រព័ន្ធស្រោចស្រព,ទឹកបរិភោគ.

## ៤. អាទិភាពមូលនិធិ

ផ្នែកនេះអាចបំពេញបានដោយឯកភាជ្យរបស់សហគមន៍

ដំបូងដាក់មូលនិធិផែនការប្រចាំឆ្នាំដែលជាប់ទាក់ទងទៅតាមក្រុម(ឧទា. ផែនការវិនិយោគឃុំសង្កាត់) ស្ថិតនៅក្រោមតម្រូវការដែលកំណត់បានក្នុងផ្នែកទីមួយ។ បន្ទាប់មក កំណត់ចំណាត់ថ្នាក់ដោយផ្អែកទៅលើកញ្ចប់ថវិការដែលមានច្រើនបំផុតទៅតិចបំផុត។ សូមមើលការកត់ត្រាចុងបញ្ចប់អំពីការបង្ហាញទិន្នន័យជាក់លាក់ចំពោះក្រុម។

| វត្ថុ | ភាគរយមូលនិធិ | ចំណាត់ថ្នាក់ផែនការ |
|---|---|---|
| ទឹកបរិភោគ | ១.៣% | ៨ |
| ការថែទាំសុខភាព | ៤.០% | ៧ |
| ការអប់រំ | ១៦.៣% | ២ |
| ជំនាញកសិកម្ម | ៦.៥% | ៤ |
| ផ្លូវ | ៥.៧% | ៦ |
| ប្រព័ន្ធស្រោចស្រព | ១៣.៩% | ៣ |
| បរិស្ថានធម្មជាតិ | ៥.៨% | ៥ |
| រដ្ឋបាល | ៤៦.៤% | ១ |

## ៥.ការប្រៀបធៀបចំណាត់ថ្នាក់

បន្ទាប់មកប្រៀបធៀបចំណាត់ថ្នាក់។ ចំណាត់ថ្នាក់ផែនការមកពីផ្នែកទី៤, ចំណាត់ថ្នាក់ភាពងាយរងគ្រោះមកពីជួរឈរចុងក្រោយគេ ផ្នែកទី៣(អាទិភាពភាពងាយរងគ្រោះពីអាកាសធាតុ)និងចំណាត់ថ្នាក់តម្រូវការមកពីផ្នែកទី១។

| វត្ថុ | ចំណាត់ថ្នាក់ផែនការ | ចំណាត់ថ្នាក់តម្រូវការ | ចំណាត់ថ្នាក់ភាពងាយរងគ្រោះ |
|---|---|---|---|
| ទឹកបរិភោគ | ៥ | ៣ | ១ |
| ការថែទាំសុខភាព | ៧ | ១ | ២ |
| ការអប់រំ | ៣ | ៣ | ៣ |
| ជំនាញកសិកម្ម | ៦ | ២ | ៤ |
| ផ្លូវ | ១ | ១ | ៥ |
| ប្រព័ន្ធស្រោចស្រព | ២ | ៣ | ៦ |
| បរិស្ថានធម្មជាតិ | ៤ | 0 | 0 |

ឥឡូវនេះអ្នករួចរាល់ហើយសម្រាប់ការពិភាក្សាជាមួយនឹងក្រុមអំពី ហេតុអ្វីចាត់ចំណាត់ថ្នាក់ខុសគ្នាៈ

i. ហេតុអ្វីចំណាត់ថ្នាក់ ផែនការ តម្រូវការនិងភាពងាយរងគ្រោះចាត់ចំណាត់ថ្នាក់ខុសគ្នា?តើការចំនាយពន្យល់ពីចំណាត់ថ្នាក់ផែនការអ្វីមួយឬទេ? ឧទាហរណ៍ ការចំណាយរបស់ប្រព័ន្ធស្រោចស្រពប្រហែលជាធ្វើអោយចំណាត់ថ្នាក់នៃផែនការខ្ពស់(វាមានតម្លៃថ្លៃ) ឬចំណាត់ថ្នាក់ផែនការទាប(វាមានតម្លៃថ្លៃខ្លាំងពេក)

ii. ប្រៀបធៀបផែនការនិងចំណាត់ថ្នាក់ភាពងាយរងគ្រោះ។តើអ្វីខ្លះដែលទទួលបានមូលនិធិតិចដែលថាពួកគេគួរតែផ្អែកទៅលើតម្រូវការ? ហេតុអ្វី? នរណាជាអ្នកទទួលខុសត្រូវក្នុងការផ្តល់នូវអ្វីទាំងអស់នេះ? តើអ្នកផ្តល់មូលនិធិទាំងអស់នោះធ្វើការកំណត់ដោយរបៀបណា? តើមានអ្វីកើតឡើងបើសិនជាមូលនិធិមិនមានឬកំពុងធ្លាក់ចុះ? ជាឧទាហរណ៍ ទឹកបរិភោគទទួលនូវចំណាត់ថ្នាក់ផែនការទាបប៉ុន្តែចំណាត់ថ្នាក់ភាពងាយរងគ្រោះខ្ពស់។ចំណុចនេះប្រហែលជាត្រូវពន្យល់ពីព្រោះអង្គការក្រៅរដ្ឋាភិបាលបានបានផ្តល់នូវអណ្តូងទឹកពីពេលមុនរួចទៅហើយ។ ឃុំត្រូវពិចារណាតើអង្គការក្រៅរដ្ឋាភិបាលនឹងបន្តអោយសម្រេចបានតម្រូវការនេះទៀតទេ។

iii. តើអ្វីដែលមានសារៈសំខាន់ជាងគេនៅពេលដែលអាកាសធាតុកាន់តែអាក្រក់ទៅនិងហេតុអ្វី(ចំណាត់ថ្នាក់ភាពងាយរងគ្រោះជួរឈរ)? តើចំណុចទាំងអស់នេះអាចដោះស្រាយនៅក្នុងសំណើរមូលនិធិដែលមានស្រាប់បានដែរឬទេ? តើចំណុចទាំងអស់នេះគួរតែដោះស្រាយដោយម្ចាស់ជំនួយដែរឬទេ? បើសិនជាអាច ដោយរបៀបណា? ជាឧទាហរណ៍ សម្រាប់ប្រព័ន្ធស្រោចស្រព ចំណាត់ថ្នាក់ភាពងាយរងគ្រោះគឺខ្ពស់ប៉ុន្តែចំណាត់ថ្នាក់ផែនការគឺទាប ពីព្រោះក្រុមហ៊ុនឯកជនបានរំពឹងទុកថានិងធ្វើនូវការអភិវឌ្ឍន៏នេះ។ ឃុំត្រូវប្រាកដថាពួកគេបានដឹងអំពីសារៈសំខាន់នៃចំណុចអាទិភាពទាំងអស់នេះ ជាពិសេសព័ត៌មានពីបម្រែបម្រួលអាកាសធាតុដែលបានផ្តល់អោយ។

### កំណត់សំគាល់: ផែនកំណត់កិច្ចពិភាក្សា

ការពិភាក្សាអំពីចំណុចអាទិភាពអាចនឹងមានការលំបាកពីព្រោះតែមានក្តីកង្វល់អំពីអំពើពុករលួយ។ពេលខ្លះអ្វីដែលត្រូវបានផ្តល់មូលនិធិអាស្រ័យទៅលើចំណុចអាទិភាពថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ។ ពេលខ្លះផែនការត្រូវបានអភិវឌ្ឍន៍ឡើងខុសពីតម្រូវការជាក់ស្តែង។ ពេលខ្លះចំណុចអាទិភាពនិងតម្រូវការមានការផ្លាស់ប្តូរក្រោយពីផែនការបានអភិវឌ្ឍន៍ឡើង(ជាឧទាហរណ៍ ពីព្រោះតែគ្រោះមហន្តរាយឬពីព្រោះតែសេវាកម្មបានល្អប្រសើរឡើង)។ ពេលខ្លះ ក្រុមប្រឹក្សាឃុំឬក្រុមនានា ប្រហែលជាមិនបានដឹងពីកញ្ចប់ថវិការ។ ពេលខ្លះកញ្ចប់ថវិការដែលមាននៅក្នុងផែនការមិនកើតឡើងក្នុងស្ថានភាពជាក់ស្តែងទេ។ ដើម្បីជៀសវាងនូវការពិភាក្សាពីចំណុចទាំងអស់នេះ ពួកយើងផ្តោតសំខាន់ទៅលើចំណុចអាទិភាព មិនមែនកញ្ចប់ថវិកាជាក់ស្តែងទេ។

ចំណុចអាទិភាពដែលមិនត្រូវគ្នាតម្រូវអោយមានការពិចារណាដោយប្រុងប្រយ័ត្នទាំងពីបុព្វហេតុនិងផលវិបាកនិងផ្នែកសំខាន់ពីភាពស្មុគស្មាញនៃផែនការ, កញ្ចប់ថវិការសម្រាប់តម្រូវការអាទិភាពប្រហែលជាមិនអាចសំរេចបានដោយរដ្ឋាភិបាលទេ។វាមានន័យថាដើម្បីដោះស្រាយបញ្ហានេះប្រហែលជាត្រូវធ្វើអោយដំណើរការមានភាពប្រសើរឡើងចំពោះការជូនដំណឹងពីចំណុចអាទិភាពអោយបានទៀងទាត់។ ចំណុចនេះបង្ហាញនៅក្នុងទិន្នន័យខាងក្រោម ដែលរង្វង់បង្ហាញពីដំណើរការផែនការ Nបង្ហាញពីចំណុចអាទិភាពថ្នាក់ជាតិ Pបង្ហាញពីចំណុចអាទិភាពថ្នាក់ខេត្ត Dបង្ហាញពីចំណុចអាទិភាពថ្នាក់ស្រុកនិង Cបង្ហាញពីចំណុចអាទិភាពថ្នាក់ឃុំ។





Layout & Design by
Battambang Traveller Group
Email: info@battambangtraveler.com
www.battambangtraveler.com